# មិត្តសំឡាញ់

**MITH SAMLANH**

# របាយការណ៍ប្រចាំឆ្នាំ២០១០

## មករា–ធ្នូ ឆ្នាំ២០១០

រៀបចំដោយៈ លោក ផេង សៅឆេង

ត្រួតពិនិត្យដោយ លោក ម៉ាន ផល្លី និងលោកស្រី ម៉ប់ សូម៉ាយ៉ា

ធ្នូ ២០១០

ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ,ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥–២៣) ២២០ ៥៩៦ ទូរស័ព្ទ/ទូរសារ: (៨៥៥–២៣)៤២៦ ៧៤៨
អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

*Mith Samlanh would like to say thanks to our sponsors:*

*- AusAid/HAARP, Credit Lyonnais Securities Asia, Child Support Network, Deutsche Bank, Danchurch Aid, EUROPEAN UNION/German Agro Action/Catholic Committee against Hunger and for Development, Evert en Gisela Boudewijn Stichting, Friends-International, French Embassy, Global Fund, Give2 Asia, Pharmaciens Sans Frontieres , La Chaine de L'Espoir, Mainline, Muslim Aid, Planet Wheeler , Riverview Children Foundation, Save the Children Australia, UNICEF, World Health Organization/ SIDA*

# បញ្ជីនៃអក្សរកាត់

| | |
|---|---|
| CCASVA | សមាគមកុមារកម្ពុជា ប្រឆាំង ទុរភិក្ស និងហិង្សា (ស៊ីកាស្វា) |
| CYTI | បណ្តាញការងាររបស់អង្គការប្រេ្រ្ទនអ៊ិនធើណាសិនណល |
| CCFD | សមាគមកាតូលិកប្រឆាំងនឹងគ្រោះទុរភិក្សដើម្បីអភិវឌ្ឍន៍ |
| DFDL | ក្រុមហ៊ុន DFDL MEKONG (Legal & Tax Advisers) |
| DU | អ្នកប្រើប្រាស់គ្រឿងញៀន |
| HBP | សិប្បកម្មតាមផ្ទះ |
| MDSAVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទារាជធានី |
| EU | សហភាពអ៊ឺរ៉ុប |
| FA | ប្រេ្រ្ទនអាល់ទ្បេអ៊ិន |
| HIV/ AIDS | មេរោគអេដស៍/ ជម្ងឺអេដស៍ |
| IEC | សំភារៈអប់រំ |
| ICC | អង្គការសហប្រតិបត្តិការអន្តរជាតិដើម្បីកម្ពុជា |
| IDU | អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ |
| MoEYS | ក្រសួង អប់រំ យុវជន និងកីឡា |
| MoSAVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា |
| MoH | ក្រសួងសុខាភិបាល |
| MMT | ការព្យាបាលឱសថជំនួសមេតាដូន |

| | |
|---|---|
| NGO GPP | គំរោងប្រតិបត្តិល្អរបស់អង្គការក្រៅរដ្ឋាភិបាល |
| NIE | វិទ្យាស្ថានជាតិអប់រំ |
| NSP | កម្មវិធីម្ជុល/ស៊ីរ៉ាំង |
| NACD | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ |
| SoP | បទដ្ឋាននៃនីតិវិធី |
| STDs | ជម្ងឺកាមរោគ |
| TA | ជំនួយការបច្ចេកទេស |
| Tooit-Tooit | ឈ្មោះតូបលក់ផលិតផលសិប្បកម្មតាមផ្ទះនៅក្នុងផ្សារទួលទំពូង លេខ ៤៣៤ |
| UNICEF | អង្គការមូលនិធិកុមារសហប្រជាជាតិ |
| WHO | អង្គការសុខភាពពិភពលោក |

ហ្វ្រេនអ្រអាល់ឡាយអ៊ិន –អង្គការមិត្តសំឡាញ់

គម្រោងកម្មវិធី

**២០០៧ -២០១១**

# លទ្ធផលសកម្មភាពប្រចាំឆ្នាំ ២០១០

| | |
|---|---|
| ទស្សនៈវិស័យ | យើងធ្វើការរួមគ្នា ដើម្បីការពារកុមារ/យុវវ័យតាមផ្លូវ និងក្រុមផ្សេងទៀតដែលពាក់ព័ន្ធ តាមរយៈការធ្វើការជាមួយពួកគេ ធ្វើអោយយើងអាចបង្កើតឱកាសថ្មីៗដែលល្អសម្រាប់កសាងអនាគតរបស់ពួកគេ។ |
| បេសកកម្ម | អង្គការមិត្តសំឡាញ់គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលបង្កើតឡើងដោយអង្គការហ្វ្រេនអ៊ិនធើណាស៊ិនណល និងជាសមាជិកហ្វ្រេនអ្រអាល់ឡាយអ៊ិន (Friends Alliance) ដើម្បីធ្វើការជាមួយកុមារ/យុវវ័យតាមផ្លូវ គ្រួសារ និងសហគមន៍របស់ពួកគេ ក្នុងគោលដៅកសាងសមត្ថភាពរបស់ពួកគេ ដែលធ្វើឡើងតាមរយៈ:<br>– **ការផ្ដល់ការការពារ** ដល់កុមារ និងយុវវ័យតាមផ្លូវពីការរំលោភបំពានគ្រប់ទម្រង់ដូចមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។<br>– **ការធ្វើសមាហរណកម្ម** កុមារ និងយុវវ័យតាមផ្លូវត្រឡប់ទៅរួមរស់ក្នុងសហគមន៍វិញ ដើម្បីពួកគេអាចចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍន៍សង្គមជាតិរបស់ពួកគេ។<br>– **ការទប់ស្កាត់** កុមារនិងយុវវ័យតាមផ្លូវមិនឱ្យចូលរួមក្នុងសកម្មភាព និង/ឬស្ថានភាពប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យប៉ះពាល់ដល់អនាគតរបស់ ពួកគេ។<br>– **ការកែលំអ** បែបបទការងាររបស់អង្គការ តាមរយៈការជំរុញឱ្យមានការផ្តួចផ្តើមថ្មីៗដែលល្អ ដោយមានការចូលរួមយ៉ាងសកម្មពីកុមារ និងក្រុមយុវវ័យ។<br>– **ការកែប្រែ**សង្គមគ្រប់ស្រទាប់វណ្ណៈទាំងអស់ ដើម្បីជំរុញឱ្យមានបរិយាកាសអំណោយផល និង ការប្រកាន់យកនូវឥរិយាបថថ្មីដែលល្អត្រឹមត្រូវ។ |

| | | |
|---|---|---|
| | ចាប់តាំងពីឆ្នាំ ១៩៩៤ មក អង្គការមិត្តសំឡាញ់ បានសហការជាមួយនឹងអង្គការហ្វ្រេនឡអ៊ិនធើណាសិនណល/សមាជិកហ្វ្រេនឡអាល់ឡៃអ៊ិន( Friends Alliance ) ដែលបាននិងកំពុងរៀបចំកម្មវិធីថ្មីៗប្រកប ដោយគំនិតច្នៃប្រឌិត និងមានលក្ខណៈពេញលេញក្នុងការកសាងបណ្តាញគាំទ្រដល់គម្រោង ដែលដឹកនាំដោយយុវវ័យ និងបង្កើតនូវសេវាការពារ និងគាំទ្រយ៉ាងរឹងមាំ នៅក្នុងអង្គការ សហគមន៍ និងនៅគ្រប់ស្រទាប់វណ្ណៈទាំងអស់របស់សង្គម ក្នុងគោលដៅធានាឱ្យបាននូវនិរន្តភាពមួយពិតៗ។ | |
| គោលបំណងទូទៅ | បង្កើតសេវាកម្មអនុវត្តន៍ល្អ ជាមួយនឹង/សម្រាប់កុមារ/យុវវ័យតាមថ្នល់ និង ក្រុមពាក់ព័ន្ធនៅក្នុងទីក្រុងភ្នំពេញ និងខេត្តកំពង់ចាម ដោយសហការយ៉ាងជិតស្និទជាមួយនឹងអាជ្ញាធរ– ទីក្រុងភ្នំពេញ និង ខេត្តកំពង់ចាម។ | |
| គោលបំណង ជាក់លាក់ | ហេតុផលនៃកិច្ចអន្តរាគមន៍ | សូចនាករដែលអាចផ្ទៀងផ្ទាត់បានយ៉ាងជាក់ស្តែងលើគោលបំណង |
| | I. ***កម្មវិធីហ្វ្រេនឡអាឡៃអ៊ិន:*** បង្កើតគម្រោងហ្វ្រេនឡអ៊ិនធើណាសិនណលយ៉ាងរឹងមាំ នៅក្នុងអង្គការមិត្តសំឡាញ់ ហើយនឹងក្លាយទៅជាគំរូនៃការអនុវត្តន៍ល្អ ដោយមានការទទួលស្គាល់ជាអន្តរជាតិ។<br>II. ***បណ្តាញការពារសុវត្ថិភាពកុមារ:*** កែលំអការការពារជារួមលើកុមារ និងយុវវ័យតាមថ្នល់នៅក្នុងទីក្រុងភ្នំពេញ និងខេត្តកំពង់ចាមតាមរយៈបណ្តាញការពារ សុវត្ថិភាពកុមារ។<br>III. ***អាជីវកម្មសង្គមហ្វ្រេនឡរកប្រាក់ចំណូល:*** បង្កើតគំរូអាជីវកម្មសង្គមនិងអាជីវកម្មតាមរយៈការណ្តុះ | ១. អង្គការមិត្តសំឡាញ់មានទំនាក់ទំនង និងផ្តល់សេវាអនុវត្តន៍ល្អបំផុតដល់កុមារនិងយុវវ័យតាមថ្នល់ ៤៥០.០០០ នាក់។<br>២. បណ្តាញការពារសុវត្ថិភាពកុមារ ប្រតិបត្តិការជាមួយនឹងដៃគូ និងសមាជិកដែលមានការទទួលស្គាល់ជាសមាជិកត្រឹមត្រូវចំនួន ៧០០រូប នៅឆ្នាំ ២០១១។<br>៣. ៦០%នៃគម្រោងមាន និរន្តភាពនៅឆ្នាំ ២០១១។ |

| | | |
|---|---|---|
| | បណ្ដាល វិជ្ជាជីវៈដែលអាចទ្រទ្រង់ទាំងស្រុងដល់និរន្តភាពផ្នែក ហិរញ្ញវត្ថុ សម្រាប់គម្រោង។ | |
| | IV. ***ការគ្រប់គ្រងរដ្ឋបាល :*** ដំណើរការអង្គការដែលមានការអនុវត្តន៍ល្អបំផុតនៅគ្រប់ផ្នែកក្នុងកិច្ចការរដ្ឋបាល។ | ៤. នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ ត្រូវបានទទួលស្គាល់ថាជាអង្គការដែលមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលល្អបំផុត។ |
| | V. ***និរន្តរភាព:*** ឆ្នាំ២០១១ អង្គការមិត្តសំឡាញ់នឹងជាម្ចាស់កម្មសិទ្ធិពេញលេញលើអចលទ្រព្យនៃមជ្ឈមណ្ឌលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំ។ | ៥. នៅឆ្នាំ២០១១ បំណុលត្រូវបានទូទាត់ក្នុងការទិញអចលនទ្រព្យ នៅក្នុងមជ្ឈមណ្ឌលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំនៃអង្គការមិត្តសំឡាញ់។ |

| | |
|---|---|
| **លទ្ធផលទី១**<br>នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh) ត្រូវបានទទួលស្គាល់ថាជាគំរូអនុវត្តន៍ល្អ បំផុតជាអន្តរជាតិ ដែលផ្ដល់នូវសេវាកម្មគ្រប់ ផ្នែកដល់កុមារ និងយុវវ័យតាមផ្លូវ(ទំនាក់ទំនង)ចំនួន ៤៥០.០០០ នាក់ ក្នុងមួយឆ្នាំ ក្រោមការសហការជាមួយនឹងអាជ្ញាធរជាតិ ដែលពាក់ព័ន្ធ។ | - ក្នុងឆ្នាំ ២០១០ អង្គការមិត្តសំឡាញ់បានធ្វើការជាមួយកុមារ/យុវវ័យជាង ១២,៧០០នាក់(ស្រី៤,៩៣១នាក់) និងបានផ្ដល់សេវាកម្មចំនួន ១,៤៦០,៨៤០ (ស្រី ៣៧១,៧៦២នាក់)។<br>- អង្គការមិត្តសំឡាញ់បាន :<br>– ផ្ដល់ការស្នាក់នៅដ៏មានសុវត្ថិភាពដល់កុមារ/យុវវ័យចំនួន ៤៩៧ នាក់ និងបានសមាហរណកម្មកុមារ/យុវវ័យ ចំនួន ១៧០នាក់ទៅកាន់គ្រួសាររបស់ពួកគេ។<br>– សមាហរណកម្មកុមារថ្មីចំនួន ៣៨៥នាក់(ស្រី១៧២នាក់) ទៅសាលារដ្ឋ និងបន្តគាំទ្រកុមារនៅសាការដ្ឋចំនួន ១,១១០ នាក់ (ស្រី៤៨២នាក់) (សរុបចំនួន ១៤៩៥នាក់)<br>– ផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់យុវវ័យចំនួន ៦៩៦នាក់ និងគាំទ្រយុវវ័យ ចំនួន១៦៥នាក់ឱ្យទទួលបានការងារធ្វើ។<br>***កំណត់សម្គាល់:*** *នៅក្នុងឯកសារនាពេលបច្ចុប្បន្ននេះ ពាក្យ "contacts" បានប្ដូរទៅ"service-events"* |

| | |
|---|---|
| | - មិត្តសំឡាញ់បានកំពុងធ្វើការសហការដ៏ល្អ ជាមួយអង្គការដៃគូ និងអាជ្ញាធរជាតិពាក់ព័ន្ធតាមការអនុវត្តសេវាកម្មគ្រប់ផ្នែករបស់ខ្លួន អង្គការមិត្តសំឡាញ់បាននឹងកំពុងអនុវត្តជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ស្នងការនគបាលរាជធានីភ្នំពេញ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិង យុវនីតិសម្បទា ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមការងារគ្រឿងញៀនពាក់ព័ន្ធមេរោគអេដស៍/ជម្ងឺអេដស៍ មន្ទីរសង្គមកិច្ចខេត្តកំពង់ចាម មន្ទីរអប់រំ យុវជន និង កីឡា សាលារៀនរដ្ឋ មជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលវប្បធម៌បារាំង ព្រះបរមរាជវាំង សារមន្ទីរជាតិ និងសារមន្ទីរទួលស្លែង តាមរយៈការប្រជុំការពិគ្រោះយោបល់ ការបណ្តុះបណ្តាលការងារសមាហរណកម្ម ទស្សនកិច្ចសិក្សា និងការផ្លាស់ប្តូរបទពិសោធន៍ លើការងារអនុវត្តជាមួយគ្នាក្នុងមូលដ្ឋានលើការងារកុមារ/យុវវ័យតាមថ្នល់។ |
| **លទ្ធផលទី២**<br>នៅឆ្នាំ ២០១១ ដៃគូបណ្តាញការពារ សុវត្ថិ ភាពកុមារ (Child Safe Network ) ចំនួន ៧០០ នឹងការពារ គាំទ្រដល់កុមារចំនួន ៥.០០០នាក់ នៅក្នុងទីក្រុងភ្នំពេញ និងខេត្តកំពង់ចាម។ | - ក្នុងឆ្នាំ២០១០ អង្គការមិត្តសំឡាញ់បានផ្តល់ការបណ្តុះបណ្តាល និងតាមដានបណ្តាញសុវត្ថិភាពកុមារនិងសមាជិកនៅភ្នំពេញ និងកំពង់ចាម សុរបចំនួន:៦៦៣ នាក់ (ថ្មី១២៩នាក់ )<br>**បណ្តាញដៃគូរសុវត្ថិភាពកុមារ**<br>– ១៩៦ នាក់ (ថ្មី ៣៣ ) ជាបុគ្គលិកធានាគារ ANZ Royal Bank<br>**សមាជិកសុវត្ថិភាពកុមារ**<br>– ភ្នំពេញ ៣៤៤ នាក់ (ថ្មី ៧១នាក់)<br>– កំពង់ចាម ១២៣នាក់ (ថ្មី ២៥នាក់)<br>- កុមារ/យុវវ័យសុរបចំនួន ៣,២៣៥០នាក់ (ស្រី១,១៧១នាក់) បានទទួលការគាំទ្រនិងការពារដោយបណ្តាញសុវត្ថិភាពកុមារនៅភ្នំពេញ និងខេត្តកំពង់ចាម។ |
| **លទ្ធផលទី៣**<br>នៅឆ្នាំ ២០១១ គម្រោងមាននិរន្តភាព ៦០% តាម | ក្នុងឆ្នាំ២០១០ អង្គការមិត្តសំឡាញ់ទទួលបាននិរន្តភាពហិរញ្ញវត្ថុចំនួន ៤៤% ដែលបានបង្កើតឡើងដោយកម្មវិធីអាជីវកម្មតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវ: និងអាជីវកម្មសង្គម ។ អាជីវកម្មបាននឹងកំពុងដំណើរការនៅក្នុងទីក្រុងភ្នំពេញ រួមមាន: |

| | |
|---|---|
| រយៈការបង្កើតកម្មវិធីអាជីវកម្ម តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈនិងអាជីវកម្មសង្គម។ | – ភោជនីដ្ឋានហ្វ្រេនឡ្យ<br>– ភោជនីដ្ឋានរំដេង<br>– កាហ្វេមិត្តសំឡាញ់<br>– ហាងលក់ទំនិញហ្វ្រេនឡ្យ អេន ស្តាហ្វ<br>– មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ<br>– សៀវភៅធ្វើមុខម្ហូប<br>– អាជីវកម្មសហគមន៍<br>* ចំណាំ: និរន្តភាពហិរញ្ញវត្ថុគឺជាប្រាក់ចំណូលដែលបានមកពីការលក់ផលិតផលនៃគំរោងអាជីវកម្ម/ការចំណាយសរុបនៃគម្រោង។ |
| **លទ្ធផលទី៤**<br>នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ (MithSamlanh ) ត្រូវបានទទួលស្គាល់ថាជាអង្គការមានប្រព័ន្ធរដ្ឋបាលល្អបំផុត។ | - អង្គការមិត្តសំឡាញ់ត្រូវបានទទួលស្គាល់ ដោយគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាលតាំងពីឆ្នាំ២០០៧ ដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (ស៊ីស៊ីស៊ី) ។ វិញ្ញាបនបត្រនេះមានសុពលភាពរយៈពេល៣ឆ្នាំ ហើយអង្គមិត្តសំឡាញ់បានដាក់ពាក្យសារឡើងវិញនៅក្នុងឆ្នាំនេះ។<br>- បទបញ្ជាផ្ទៃក្នុងរបស់អង្គការមិត្តសំឡាញ់បានបញ្ចប់ និងបានការឯកភាពពីសមាជិកក្រុមប្រឹក្សាភិបាល បន្ទាប់មកបានធ្វើបទបង្ហាញជូនដល់ប្រធានក្រុម អ្នកគ្រប់គ្រប់គំរោង និងគណៈគ្រប់គ្រង់ទាំងអស់នៅក្នុងឆ្នាំនេះ។ |

| | |
|---|---|
| **លទ្ធផលទី៥**<br>នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh ) ទទួលបានកម្មសិទ្ធិទាំងស្រុងលើអចលនទ្រព្យ និងបានសាងសង់មជ្ឈមណ្ឌល ដែលផ្តល់នូវបរិយាកាសប្រកបដោយគុណភាពសម្រាប់ការងាររបស់ខ្លួន។ | - យុទ្ធការទិញដីនៃអង្គការមិត្តសំឡាញ់បានបញ្ចប់ដោយជោគជ័យ ដោយមានការគាំទ្រពីអង្គការ ហ្វ្រេនឡអ៊ិនធើណាសិនណល ជាលទ្ធផលអង្គការមិត្តសំឡាញ់បានទូរទាត់សងធនាគារ ANZ Royal រួចរាល់អស់ហើយ តាមរយៈការផ្តល់កម្ចីបន្ថែមស្មើរ៣២៥,០០០ដុល្លារ ពីម្ចាស់មូលនិធិនៃ អង្គការដៃគូរមួយចំនួន និងសងវិញរយៈពេល៤ឆ្នាំជាមួយការប្រាក់ ២ ភាគរយ។<br>- អង្គការមិត្តសំឡាញ់បានទំនាក់ទំនងជាមួយ DFDL ក្នុងការរៀបចំឯកសារអចលនៈទ្រព្យរបស់យើង ដើម្បីយកសិទ្ធិកាន់កាប់ស្របច្បាប់ជាក្រុមហ៊ុនមិត្តសំឡាញ់។ |

| **សកម្មភាព** | **លទ្ធផលរំពឹងទុក** | **លទ្ធផលសំរេចបាន** |
|---|---|---|
| **លទ្ធផលទី១: នៅឆ្នាំ ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh ) ត្រូវបានទទួលស្គាល់ថាជាគំរូអនុវត្តន៍ល្អបំផុតជាស្តង់ដារអន្តរជាតិ ដែលផ្តល់នូវសេវាកម្មគ្រប់ផ្នែកដល់កុមារ និងយុវវ័យតាមផ្លូវដែលនឹងត្រូវធ្វើ (ទំនាក់ទំនង) ចំនួន ៤៥0.000 នាក់ក្នុងមួយឆ្នាំក្រោមកិច្ចសហការជាមួយនឹងអាជ្ញាធរជាតិដែលពាក់ព័ន្ធ។** | | |
| ១.១ បទដ្ឋាននីតិវិធី (SoPs ) នៃ កម្មវិធីហ្វ្រេនឡអ៊ិនធើណាសិន ណលត្រូវបានអនុវត្តក្នុងគម្រោងរបស់អង្គការមិត្តសំឡាញ់ (Mith Samlanh ) ទាំងអស់។ | - បទដ្ឋាននីតិវិធី (SoPs ) នៃសេវាកម្មមូលដ្ឋានទាំងអស់ត្រូវបានអនុវត្តនៅឆ្នាំ ២០០៩ | - បទដ្ឋាននៃនិតិវិធី **(SoPs)** សំរាប់គម្រោងមួយចំនួន ក្នុងអង្គការមិត្តសំឡាញ់កំពុងអនុវត្តរួមមាន:<br>– បទដ្ឋាននៃនិតិវិធីការពារកុមារ<br>– បទដ្ឋាននៃនិតិវិធីរបស់គម្រោងតាមផ្លូវ<br>– បទដ្ឋាននៃនិតិវិធីសំរាប់ឱសថបន្សាប និងការប្រើប្រាស់ ហើយនិងមាត្រដ្ឋានកាត់បន្ថយការឈឺចាប់។<br>- បទដ្ឋាននៃនិតិវិធី (SoPs) និងសៀវភៅណែនាំសំរាប់គម្រោងមួយចំនួនទៀត ក្នុងអង្គការមិត្តសំឡាញ់កំពុងព្រាង និងកែសម្រួលរួមមាន:<br>– សៀវភៅណែនាំសំរាប់មណ្ឌលសំចត |

| | | |
|---|---|---|
| | - បទដ្ឋាននីតិវិធី (SoPs ) នៃសេវាកម្មមូលដ្ឋានទាំងអស់ត្រូវបានធ្វើឱ្យប្រសើរឡើងជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ ២០១០ | - សៀវភៅណែនាំសំរាប់ការគ្រប់គ្រង់ករណី<br>- សៀវភៅណែនាំសំរាប់ការធ្វើសមាហរណកម្មទៅសាលា និងគ្រួសារ។<br>- សៀវភៅណែនាំសំរាប់មណ្ឌលស្នាក់នៅបណ្តោះអាសន្ន<br>- សៀវភៅណែនាំសំរាប់បំណិនជីវិត<br>- សៀវភៅណែនាំសំរាប់ការសមាហរណកម្មការងារ<br>បទដ្ឋាននៃនិតិវិធីសំរាប់មេរោគអេដស៍/ជម្ងឺអេដស៍<br>- បទដ្ឋាននៃនិតិវិធី មិនទាន់បានបង្កើត និងដំណើរការសំរាប់សេវាកម្មទាំងអស់នោះទេ ដូច្នេះហើយពុំមានលទ្ធផលក្នុងការរាយការណ៏ទេ។ |
| ១.២ផ្តល់សេវាអនុវត្តន៍ល្អបំផុតដល់កុមារ និង យុវវ័យតាមថ្នល់ចំនួន ៤៥០.០០០ នាក់ /មួយឆ្នាំ។ | - ម្មវិធីនេះផ្តល់នូវសេវាសមាហរណកម្មសង្គមជាស្ទូលរួមមាន (គំរោងបង្ការទប់ស្កាត់/សមាហរណកម្ម/តាមថ្នល់/ផ្ទះស្នាក់នៅបណ្តោះអាសន្ន/ការអប់រំ/គ្រឿងញៀន/សមាហរកម្ម ដល់កុមារនិងយុវវ័យតាមថ្នល់ចំនួនៈ៤៥០.០០០នាក់ដែលគិតជាចំនួនសេវាទិនាក់ទំនងក្នុងមួយឆ្នាំ<br>- ចំនួនកុមារ/យុវវ័យ៧.៥០០នាក់ ទទួលបានសេវាកម្មនៅឆ្នាំ២០១១ | - កម្មវិធីបានបែងចែកជា ៤គំរោងសំខាន់ៗ ដើម្បីផ្តល់ការបង្កាទប់ស្កាត់ ការពារ និងសេវាសមាហរណកម្ម :<br>- គំរោងតាមថ្នល់ (រួមបញ្ចូលមណ្ឌលសំចត)<br>- គំរោងស្នាក់នៅ ( មណ្ឌលស្នាក់នៅបណ្តោះអាសន្ន)<br>- គំរោងអប់រំ (មជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ)<br>- គំរោងសមាហរណកម្ម (សមាហរណកម្មទៅគ្រួសារ សាលារ និងការងារ)<br>- គំរោងទទួលបានការគាំទ្រពីក្រុមឯកទេសដែលមានជំនាញ និងបទពិសោធន៍លើផ្នែកនីមួយៗរួមមានៈ គ្រឿងញៀន អប់រំក្រៅប្រពន្ធ័ បំណិនជីវិត មេរោគអេដស៍/ជម្ងឺអេដស៍ ការព្យាបាល.. |

| | | |
|---|---|---|
| | - សេវាកម្មជាក់លាក់ទៅតាមតម្រូវការត្រូវបានកំណត់ និងបង្កើតឡើង និងផ្តល់ជូន | - កុមារ/យុវវ័យជាង ១២,៧០០នាក់ (ស្រី៤០%)បានទទួលផលពីកម្មវិធីនៅក្នុងឆ្នាំ២០១០ បើធៀបទៅនឹង ឆ្នាំ២០០៩ មានការថយចុះ។នៅក្នុងឆ្នាំ២០០៩ កុមារ/យុវវ័យជាង១៩,២០០នាក់បានទទួល ផលពីកម្មវិធី។ ការធ្លាក់ចុះនេះកំណត់ឱ្យឃើញពីគុណភាពនៃការប្រមូលទិន្នន័យ។<br>- សេវាជាង១,៤៦០,៨៤០ (ស្រី ៣៧១,៧៦២នាក់)បានផ្តល់ដល់កុមារ/យុវវ័យក្នុងឆ្នាំនេះ។ ពាក់ពន្ធ័ចំនួនកុមារមានការថយចុះនៅក្នុងឆ្នាំ២០០៩ ដោយសារតែការកំណត់និយមន័យនៃសេវានិងកំពុងពង្រឹងទៅលើគុណភាពនៃការប្រមូលទិន្នន័យ។<br><br>❶ **<u>តាមថ្នល់</u>**<br>សេវាសុរបចំនួន ៦១០,៧៤៤ដង (ស្រី ១៦៤,៦០៣ដង)បានផ្តល់ជូនដល់កុមារ/យុវវ័យសុរបចំនួន ៨,២២១នាក់(ស្រី៣,៣០២នាក់)។ ក្រុមកាងារតាមថ្នល់បានជួបកុមារ/យុវវ័យថ្មីចំនួន ១,៥៧០នាក់ (ស្រី៧៥៨នាក់) និងឪពុក/ម្តាយចំនួន ១,៥៤៩ ដែលកំពុងរស់នៅ និងធ្វើការតាមថ្នល់ និងសហគមន៍នៅតំបន់គោលដៅសំខាន់ៗចំនួន៥តំបន់ និងតំបន់នីមួយមានមណ្ឌលសំចតមួយលើសពីនេះទៀតយើងមានមណ្ឌលសំចតចល័តចំនួន២ដើម្បីគាំទ្រតំបន់នីមួយៗដល់ក្រុមការងារតាមថ្នល់។<br><br>១. សេវាផ្តល់ដល់កុមារនៅតាមថ្នល់ និង សហគមន៍:<br>- បំណិនជីវិត : ១០៩,៧៣៣ ដង( ស្រី ៣២,៩១២ ដង)<br>- ការព្យាបាលៈ ២៥,៧២២ដង(ស្រី ៧,៩២២ ដង)<br>- សកម្មភាពកំសាន្តសប្បាយ : ៦២,៩៦៨ ដង (ស្រី ២២,៣២៣ ដង) |

| | | |
|---|---|---|
| | | - ការកាត់បន្ថយភាពមានគ្រោះគ្រឿងញៀនតាមថ្នល់ះ៧៦,៩៧៧ ដង (ស្រី ១៣,៣៤៥ ដង)<br><br>២. ការគាំទ្រគ្រួសាររស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍<br>- សេវាចំនួន ៣,៧៧៦ដង (ស្រី២,២៣៩ដង) បានផ្តល់ដល់ឪពុក/ម្តាយចំនួន២២១នាក់ (ស្រី ១៤១ នាក់) ជាគ្រួសាររស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍ ក្នុងនោះចំនួនសេវា ៥៨២ដង (ស្រី ២៩៧ដង) បានផ្តល់ជូនកុមារ/យុវវ័យចំនួន ៦០នាក់ (ស្រី៣០នាក់)។<br><br>- ការគាំទ្រគ្រួសាររស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍ត្រូវបានពង្រឹងក្នុងឆ្នាំ២០១០ ជាពិសេសចាប់ផ្តើមពីក្រុមគាំទ្រក្រុមសម្រាប់អាណាព្យាបាល។ ពួកគេបានទទួលជោគជ័យ និងធ្វើឱ្យអាណាព្យាបាលចំនួន ២០០ នាក់បានទទួលផល។<br><br>៣. មិត្តអប់រំមិត្ត<br>- មិត្តអប់រំមិត្តសរុបចំនួន ១៨៥ នាក់ (ស្រី ៦៤នាក់) ក្នុងនោះមានថ្មីចំនួន ១០៣នាក់ (ស្រី៣៤នាក់) ហើយមិត្តអប់រំមិត្តចំនួន ២៥នាក់ (ស្រី៧នាក់) បានបោះបង់។<br>- មិត្តអប់រំមិត្តនៅសល់សរុប ១៦០នាក់ (ស្រី៥៧នាក់) បានបន្តការអប់រំស្តីពីសុខភាពបន្តពូជការពាររោគមេរោគអេដស៍/ជម្ងឺអេដស៍ និងគ្រឿងញៀនដល់កុមារ/យុវវ័យចំនួន ១៤,៩០២ ដង (ស្រី៦,០៧៥ ដង) និងគ្រួសារចំនួន ៥,១៦៨ ដង (ស្រី ២,០៦៧)។<br>- ស្រោមអនាម័យសរុបចំនួន ១៩៤,៣៦៣ ស្រោម បានចែកចាយដល់ក្រុមគោលដៅតាមរយៈបុគ្គលិកមិត្តអប់រំមិត្ត និងភ្នាក់ងារសុវត្ថិភាព។<br><br>៤. ការបញ្ជូន: |

| | | |
|---|---|---|
| | | - កុមារ/យុវវ័យតាមថ្នល់ និង សហគមន៍សុរុបចំនួន ៨០១នាក់ (ស្រី២៥៥នាក់) បានសំរេចចិត្តចាកចេញពីតាមថ្នល់ និងបញ្ជូនទៅរៀននៅមជ្ឈមណ្ឌលអប់រំចំនួន ៣៧៧នាក់ (ស្រី១៥៦នាក់)និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៤២៤នាក់(ស្រី៩៩នាក់) របស់អង្គការមិត្តសំឡាញ់។<br>- កុមារ/យុវវ័យ និងឪពុក/ម្តាយចំនួន ៤៥៧នាក់ (ស្រី១១៧នាក់) បានគាំទ្រដើម្បីទទួលសេវាធ្វើតេស្តឈាមរកមេរោគ អេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសង្កាត់។<br><br>៥.ការព្យាបាលគ្រឿងញៀន<br>- អ្នកប្រើប្រាស់គ្រឿងញៀនត្រូវបានគាំទ្រតាមរយៈសេវាកាត់បន្ថយភាពមានគ្រោះថ្នាក់ដោយគ្រឿងញៀននៅតាមថ្នល់ និងសហគមន៍<br><br>- កុមារ/យុវវ័យ មានឆន្ទះចង់បោះបង់ចោលការប្រើប្រាស់គ្រឿងញៀននៅពេលពួកគេបានទទួលសេវានៅផ្ទះបៃតង។ ផ្ទះបៃតង ជាមជ្ឈមណ្ឌល ដែលមានកម្មវិធីព្យាបាល/បន្សាប និង ស្តារនីតិសម្បទាមានទីតាំងស្ថិតនៅជាយរាជធានីភ្នំពេញ។<br><br>- បានផ្តល់សេវាសុរុប ១២៨,១១៩ ដង(ស្រីចំនួន ២៥,៥៥៧ដង) ដល់មានកុមារ/យុវវ័យសុរុបចំនួន២០៧ នាក់(ស្រី១៩នាក់) ដែលជាអ្នកប្រើប្រាស់គ្រឿងញៀននៅតាមថ្នល់ និងសហគមន៍ក្នុងនោះមានអ្នកចាក់តាមសរសៃ សុរុប ៤៤ នាក់ (ស្រី ៧នាក់)ទទួលបានសេវាព្យាបាល/បន្សាប និងសេវាកាត់បន្ថយភាពគ្រោះថ្នាក់។<br><br>❷ **<u>មណ្ឌលស្នាក់នៅបណ្តោះអាសន្ន</u>** |

| | | |
|---|---|---|
| | | – នៅដើមឆ្នាំ មិត្តសំឡាញ់បានដំណើរការមណ្ឌលស្នាក់នៅចំនួន៤ ដែលបានផ្តល់ការស្នាក់នៅដោយសុវត្ថិភាពដល់កុមារ/យុវវ័យចំនួន ៤៩៧ នាក់ (ស្រី ២៤%)<br>– ជាមធ្យមមានកុមារចំនួន ២៥០ (ស្រី៥២នាក់) បានស្នាក់នៅក្នុងមួយខែ។<br><br>ក៏ប៉ុន្តែនៅចុង ខែធ្នូ ឆ្នាំ២០១០ មណ្ឌលស្នាក់នៅបណ្តោះអាសន្នទី៣ ត្រូវបានបិតដោយសារអត់មានមូលនិធិ ដូច្នេះកុមារទាំងអស់បានផ្ទេរទៅមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ដែលមានស្រាប់ចំនួន៣ ផ្សេងទៀត។ មណ្ឌលនីមួយៗអាចឱ្យកុមារស្នាក់នៅពី៨០នាក់ ទៅ១០០នាក់ ។<br><br>**❸ គំរោងអប់រំ**<br>– កុមារចំនួន ៦៤៧ នាក់ (ស្រី ៤០ %) បានសិក្សានៅមជ្ឈមណ្ឌលអប់រំ។<br>មជ្ឈមណ្ឌលអប់រំមាន ៨ ថ្នាក់នៃកំរិតផ្សេងៗគ្នា។ ៦ថ្នាក់ ដើម្បីគាំទ្រកុមារឱ្យចូលរៀននៅសាលារដ្ឋបាន និង២ថ្នាក់បំប៉នសំរាប់គាំទ្រកុមារដែលបានចូលរៀននៅសាលារដ្ឋរួចហើយ។<br>យុវវ័យចំនួន ៦៩៦ (ស្រី២៥ %) បានរៀនជំនាញនៅជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមាន ១០ ជំនាញ រួមមានៈ ថ្នាក់ចុងភៅ កាត់សក់ សំអាងការ បោកគក អគ្គិសនី អេឡិត្រូនិច ជួសជុលឡាន ម៉ូតូ កាត់ដេរ និងផ្សារដែក។<br><br>ក្រៅពីការសិក្សារបស់ពួកគេ កុមារ/យុវវ័យទាំងអស់បានចូលរួមសកម្មភាពកម្សាន្តសប្បាយ រួមមានៈ រាំ សិល្បៈ គូរគំនូរ ផាត់ពណ៌ កីឡា ទស្សនកិច្ច និងបណ្ណាល័យនៅក្លឹបហ្វ្រេន្ឋ ថែមទាំងពួកគេអាចទទួលបានការពិគ្រោះយោបល់ ការព្យាបាល និងសកម្មភាពបំណិនជីវិត។<br><br>កុមារ/យុវវ័យទាំងអស់បានទទួលការគាំទ្រកំឡុងពេលការសិក្សារបស់ពួកគេ ដើម្បីរៀបចំ |

| | | |
|---|---|---|
| | | សមាហរណកម្មទៅសាលារដ្ឋ ការងារ និងធ្វើអាជីវកម្មដោយខ្លួនឯង។<br><br>❹ **សមាហរណកម្ម**<br>– កុមារចំនួន ១៧០ នាក់បានសមាហរណកម្មនៅគ្រួសារ។<br>– កុមារចំនួន ៣៨៥ នាក់ បានសមាហរណកម្មទៅសាលារដ្ឋ។<br>– យុវវ័យចំនួន ១៦៥នាក់ បានសមាហរណកម្មទៅការងារ និងគាំទ្រសម្ភារៈដើម្បីចាប់ផ្តើមអាជីវកម្មរបស់ពួកគេ។<br>– ក្រុមការងារបានផ្តល់ការគាំទ្រដល់កុមារ/យុវវ័យ គ្រួសារសំរាប់សមាហរណកម្ម ការសួរសុខទុក្ខទៀងទាត់ ដើម្បីធានាលើការសមាហរណកម្មប្រកប ដោយជោគជ័យនៅតាមខេត្តនានា។<br>– គម្រោងនៅខេត្តកំពង់ចាមបានផ្ទេរទៅឱ្យមន្ទីរសង្គមកិច្ចនៅខែធ្នូ ឆ្នាំ២០១០។ គម្រោងនេះការផ្តួចផ្តើមដោយមិត្តសំឡាញ់តាំងពីឆ្នាំ២០០៥ និងដំណើរការរួមគ្នាជាមួយសង្គមកិច្ចខេត្ត ក្នុងគោលបំណងដើម្បីការពារការចំណាកស្រុកមានសុវត្ថិភាពនៃកុមារ/យុវវ័យរងគ្រោះនៅខេត្តកំពង់ចាម។ មិត្តសំឡាញ់នឹងបន្តផ្តល់ការគាំទ្រដល់មន្ទីរសង្គមកិច្ចសម្រាប់ដំណើរការគំរោង។ |
| | - ប្រវត្តិរបស់កុមារតាមផ្លូវ និងការស្រាវជ្រាវស្តីពីបញ្ហាពាក់ព័ន្ធផ្សេងៗត្រូវបានបោះពុម្ពផ្សាយ | - កម្រងឯកសារកុមារតាមផ្លូវ២០០៩ បានបញ្ចប់ ដែលជាផ្នែកនៃបណ្តាញអ្នកធ្វើការងារជាមួយកុមារតាមផ្លូវនៅកម្ពុជា ដោយមានការគាំទ្រពីប្រូវេនអ៊ិនធើណាសិនណល ហើយលទ្ធផលបានបង្ហាញដល់អង្គការដៃគូរួចហើយ។<br>- មិត្តសំឡាញ់បានចាប់ផ្តើមប្រមូលទិន្នន័យសំរាប់ធ្វើការអង្កេតឥតព្រៀងទុកប្រចាំឆ្នាំជាមួយកុមារ/យុវវ័យ ដែលកំពុងរស់នៅ និងធ្វើការ នៅតាមផ្លូវ និងសហគមន៍ ដោយសហការជាមួយ |

| | | |
|---|---|---|
| | | បណ្តាញអ្នកធ្វើការងារជាមួយកុមារតាមថ្នល់នៅកម្ពុជា។ សរុបកុមារ/យុវវ័យចំនួន ២,៤០០នាក់ (ស្រី៧៦៧នាក់) ត្រូវបានសម្ភាសន៍ នាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០។<br>- ប្រធានគម្រោងតាមថ្នល់ សហការជាមួយអ្នកសម្របសម្រួលគម្រោងគ្រឿងញៀនធ្វើការ អង្កេតគ្រឿងញៀនឥតព្រៀងទុកប្រចាំឆ្នាំ ជាមួយកុមារ/យុវវ័យដែលកំពុងរស់នៅ និងធ្វើការនៅតាមថ្នល់។ សរុបកុមារ/យុវវ័យចំនួន ៣,៦៨៩ នាក់(ស្រី១,៣១២នាក់) ត្រូវបាន សម្ភាសន៍នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។ |
| | - កម្មវិធី និងគំរោងត្រូវបានវាយតំលៃ និងតាមដានជាបន្តបន្ទាប់ ដើម្បីធានានូវការអនុវត្តន៍ ដែលល្អបំផុត | - អ្នកវាយតម្លៃខាងក្រៅរបស់គម្រោង (CCFD/EU) បានវាយតម្លៃគម្រោងអប់រំក្រៅប្រព័ន្ធ នាថ្ងៃទី១៥–៣០ខែមីនា ឆ្នាំ២០១០ ដើម្បីធានាលើដំណើរការគម្រោងបន្ទាប់ពីការវាយតម្លៃចុងក្រោយ។ លទ្ធផល និងអនុសាសន៍នៃការវាយតម្លៃរួមមានៈ<br>– លទ្ធផលរំពឹងទុកនៃគម្រោងបានសម្រេច<br>– ផ្តល់ការគាំទ្រដល់គ្រូបង្រៀននៅមិត្តសំឡាញ់ដើម្បីបង្កើតសកម្មភាពថ្មី និងដោះស្រាយបញ្ហាជាមួយកុមារ<br>– បន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាដើម្បីគាំទ្រគ្រូនៅសាលារដ្ឋដើម្បី ប្រើយុទ្ធសាស្រ្តសិស្សមជ្ឈមណ្ឌល<br>– ឯកសារ និងផ្សព្វផ្សាយសម្ភារៈ/ឧបករណ៍អនុវត្តន៍ល្អ បង្កើតឡើងដោយមិត្តសំឡាញ់ |
| | - ក្រុមការងារទទួលបានការបណ្តុះបណ្តាល ជាបន្តបន្ទាប់ និងគាំទ្របច្ចេកទេស។ | - ប្រូហ្វេនស្យុអ៊ិនធើណាសិនណលបានធ្វើការវាយតម្លៃលើគម្រោងតាមថ្នល់របស់អង្គការមិត្តសំឡាញ់ ក្នុងគោលបំណងដើម្បីតាមដាន និងពង្រឹងគុណភាពសេវានៃក្រុមតាមថ្នល់នាខែធ្នូ ឆ្នាំ២០១០។ លទ្ធផល |

| | | |
|---|---|---|
| | | និងអនុសាសន៍នៃការវាយតម្លៃរួមមានៈ<br>- ធ្វើអន្តរាគមន៍នៃក្រុមតាមផ្ទាល់ដើម្បីស្របតាមតំរូវការនៃក្រុមគោលដៅ<br>- បំណិនជីវិតគួរធ្វើឱ្យចាប់អារម្មណ៍និងធ្វើការកែសំរួលជាញឹកញាប់<br>- សកម្មភាពអប់រំក្រៅប្រពន្ធ័គួរពង្រឹងតាមរយៈសម្ភារៈថ្មី<br><br>- ម្ចាស់មូលនិធិដែលបានមកទស្សនកិច្ចនៅក្នុងឆ្នាំនេះ រួមមានៈ<br>- Muslim Aid នាថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១០<br>- សហភាពអ៊ឺរ៉ុប នាថ្ងៃទី ៣ ខែមីនាឆ្នាំ២០១០<br>- CCFD នាថ្ងៃទី ៣០-៣១ ខែសីហាឆ្នាំ២០១០<br>- Planet Wheeler នាថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១០<br>ក្នុងឆ្នាំនេះ ជាមធ្យមបុគ្គលិកទាំងអស់បានទទួលការបណ្តុះបណ្តាលចំនួន ២ដង។ បុគ្គលិកសរុបចំនួន ៥២០នាក់ (ស្រី ២២១នាក់) បានទទួលការបណ្តុះបណ្តាលផ្សេងៗ។<br><br>ការបណ្តុះបណ្តាលខាងក្នុង ផ្តល់ដោយមិត្តសំឡាញ់និងហ្វ្រេន្ឌអ៊ិនធើណាសិនណលលើប្រធានបទផ្សេងៗ ដូចជាៈ ការថែទាំជំនួស មូលដ្ឋានគ្រឹះនៃការ ប្រើប្រាស់គ្រឿងញៀន ការគ្រប់គ្រងករណី ការរំលឹកពីគោលនយោបាយការពារកុមារ ទំនាក់ទំនង នៃការធ្វើការជាក្រុម ការបង្កើតសកម្មភាពកំសាន្ត ទំរង់បន្ថែម សំរាប់អ្នករស់នៅជាមួយមេរោគ អេដស៍/ជម្ងឺអេស៍ សង្គ្រោះបឋម ការបង្រៀននិង ការតាមដាន សុខភាពបន្តពូជ កាមរោគ មេរោគអេដស៍/ជម្ងឺអេដស៍ បច្ចេកទេសនៃការសិក្សា វិធីសាស្ត្រលើការ ធ្វើការជាមួយកុមារតាមថ្នល់ សុខភាពមាត់ធ្មេញ និងច្បាប់រលូតកូន និងវគ្គបណ្តុះបណ្តាលអ្នក អប់រំលើការធ្វើការជាមួយកុមារតាមថ្នល់។ |

| | | |
|---|---|---|
| | | ប្រេហ្វន្យអ៊ិនធើណាសិនណលបានបន្តការគាំទ្រនៅផ្នែកមួយចំនួនរួមមានៈ ការងារសង្គម ការគ្រប់គ្រងករណីសកម្មភាពបង្កើនប្រាក់ចំណូល ការបណ្តុះបណ្តាលជំនាញជីវៈ និងការបណ្តុះបណ្តាលផ្នែកចុងភៅ។<br><br>ប្រេហ្វន្យអ៊ិនធើណាសិនណលបានផ្តល់ការគាំទ្របន្ថែមទៅលើផ្នែកមួយចំនួន រួមមានៈ ការគ្រប់គ្រងថវិការ និតិវិធីគណនេយ្យ ធនធានមនុស្ស ការគ្រប់គ្រងគម្រោង ទំនាក់ទំនង ការរៃអង្គាសថវិការ និងទំនាក់ទំនងជាមួយម្ចាស់ជំនួយ។<br><br>លើសពីនេះទៀតមានបុគ្គលិក៨០នាក់ (ស្រី៤០នាក់)បានទទួលការបណ្តុះបណ្តាលនៅខាងក្រៅ ដែលផ្តល់ការគាំទ្រថវិកាពីម្ចាស់ជំនួយ និងអង្គការដៃគូផ្សេងៗ លើប្រធានបទៈ មេតាដូន ការ តស៊ូមតិក្មេងប្រុសជាចំបង ការគ្រប់គ្រងអាជីវកម្ម ភាសាអង់គ្លេសទូទៅ អភិបាលកិច្ច ការអភិវឌ្ឍន៍ក្រុមប្រឹក្សាភិបាល ការគ្រប់គ្រងគោដនីយដ្ឋាន ការគ្រប់គ្រងហិរញ្ញវត្ថុផ្នែកក្នុងសិក្សា កម្មវិធីកុំព្យូទ័រឃ្វីកប៊ុក និងការគ្រប់គ្រងបុគ្គលិក ។ |
| ១.៣ គាំទ្រដល់កុមារ/យុវវ័យ តាមថ្នល់ ១,០០០ នាក់ក្នុងមួយឆ្នាំក្នុងការបញ្ជូនកុមារទៅរួមរស់ក្នុងសង្គមវិញ(គ្រួសារនិង/ឬសាលារៀន ឬ ការងារ និងជាមួយប្រជាពលរដ្ឋល្អ) និងតាមដានកុមារនិងយុវវ័យតាម | - កុមារ ៣៥០នាក់ ត្រូវបានបញ្ជូនទៅចូលរៀនក្នុងសាលារដ្ឋ ក្នុងមួយឆ្នាំនៅត្រីមាស ទី៤នៃឆ្នាំ ២០១១<br>- កុមារ ១៥០០នាក់ ត្រូវបានជួយគាំទ្រឱ្យនៅរៀនក្នុងមួយឆ្នាំ នៅត្រីមាសទី៤ នៃឆ្នាំ២០១១ | **សមាហរណកម្មទៅសាលារដ្ឋ**<br>- កុមារថ្មីចំនួន ៣៨៥នាក់ (ស្រី១៧២នាក់) បានបញ្ជូនទៅចូលរៀនក្នុងសាលារដ្ឋ ក្នុងមួយឆ្នាំ ២០១០ (កុមារចំនួន ៣៧៤ នាក់នៅឆ្នាំ២០០៩)<br>- កុមារចំនួន ១,១១០នាក់ (ស្រី៤៨២នាក់) បានបន្តការគាំទ្រឱ្យនៅរៀនសាលារដ្ឋ។ កុមារចំនួន ៩៣ % បានបន្តជួយគាំទ្រឱ្យនៅរៀនសាលាបន្ទាប់ពីបានសមាហរកម្មអស់រយៈពេលមួយឆ្នាំ។<br><br>- កុមារទាំងអស់បានទទួលសម្ភារៈសិក្សា និងបន្តការចុះតាមដានសួរសុខទុក្ខយ៉ាង ទៀងទាត់ទាំងនៅរាជធានីភ្នំពេញ និង បណ្តាខេត្តនានា។ |

| | | |
|---|---|---|
| ថ្នល់ ២,៥០០នាក់បន្ថែមទៀត ដែលបានគាំទ្រពីមុនមក។ | - យុវវ័យតាមថ្នល់ ១៥០នាក់ រកការងារបានធ្វើក្នុងមួយឆ្នាំនៅត្រីមាសទី៤ នៃឆ្នាំ២០១១ | **សមាហរណកម្មទៅធ្វើការ និងប្រកបការងារដោយខ្លួនឯង**<br>- កុមារចំនួន ១៦៥នាក់ (ស្រី៤៦នាក់) បានដាក់អោយមានការងារធ្វើ និងប្រកបការងារដោយ ខ្លួនឯងៈ<br>– ១០៨ នាក់ (ស្រី ៣៤នាក់) បានដាក់ឱ្យធ្វើការនៅតាមហាង ។<br>– ៥៧នាក់ (ស្រី ១២នាក់) បានដាក់ឱ្យរកស៊ីដោយខ្លួនឯង។<br>– ៩៤នាក់ (ស្រី ១៧នាក់) បានបញ្ចប់កម្មវិធីសិក្សាដោយជោគជ័យនិងសិស្សខ្លះទៀតបានសំរេចចិត្តចាកចេញមុនពេល ដើម្បីស្វែងរកការងារធ្វើ និងប្រើប្រាស់ជំនាញ ដែលពួកគេមានស្រាប់។ |
| | - កុមារ/យុវវ័យតាមថ្នល់ ១.០០០ នាក់ ត្រូវបានធ្វើសមាហរណកម្មទៅរួមរស់ក្នុងសហគមន៍វិញ/គាំទ្រចូលទៅក្នុងគ្រួសារ (គ្រួសារផ្ទាល់/ គ្រួសារសាច់ញាតិ/ គ្រួសារធម៌រួមទាំងចូលសាលាឬធ្វើការ) ក្នុងមួយឆ្នាំនៅត្រីមាសទី៤នៃឆ្នាំ២០១១ | **សមាហរណកម្មទៅគ្រួសារ**<br>- កុមារ/យុវវ័យតាមថ្នល់ ១៧០នាក់ (ស្រី៤៥នាក់) បានធ្វើសមាហរណកម្មទៅគ្រួសារ ។<br>១. កុមារ/យុវវ័យចំនួន ៨៨ នាក់ (ស្រី ២៧នាក់) បញ្ជូនទៅគ្រួសារពួកគាត់ផ្ទាល់<br>– ៣១នាក់ (ស្រី១៨នាក់) បានដាក់អោយមានការងារធ្វើ។<br>– ៣៤ (ស្រី១០នាក់) សមាហរណកម្មទៅសាលារដ្ឋ<br>– ២៣នាក់ ទទួលបានការគាំទ្រ និងការធ្វើសមាហណកម្មភ្លាមៗ បន្ទាប់ពីផ្សះផ្សាគ្រួសាររួច ។<br>២.កុមារ/យុវវ័យចំនួន ២៩នាក់ (ស្រី៤នាក់) បានបញ្ជូនទៅគ្រួសារសាច់ញាតិ ។<br>– ១០នាក់ (ស្រី ២នាក់) បញ្ជូនទៅធ្វើការរកស៊ីដោយខ្លួនឯង។<br>– ១៩នាក់ (ស្រី២នាក់) បានការគាំទ្រ និងធ្វើសមាហរណកម្មភ្លាមៗ។<br>៣.កុមារ/យុវវ័យ៦ នាក់ (ស្រី ២នាក់) បានបញ្ជូនទៅគ្រួសារធម៌នៅខេត្តកណ្តាល និងភ្នំពេញ។<br>៤.កុមារ/យុវវ័យ៤៦ នាក់ (ស្រី១២នាក់) បានបញ្ជូនទៅរស់នៅដោយឯករាជ្យ និងរកការងារ |

| | | |
|---|---|---|
| | | ធ្វើដោយខ្លួនឯង។<br>៥.យុវវ័យ ១នាក់ បានសមាហរណកម្មទៅអង្គការអង្គការកម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់នៅខេត្តកំពង់ចាម។ |
| | - កុមារ/យុវវ័យតាមផ្លូវ ចំនួន ១.000 នាក់ដែលមិត្តសំឡាញ់ត្រូវបានឧបត្ថម្ភដល់គ្រួសារក្នុងមួយឆ្នាំ នៅត្រីមាសទី៤ នៃឆ្នាំ ២0១១ | - កុមារ/យុវវ័យសរុប ៦១៣ នាក់(ស្រី២២៥នាក់) បន្តជួយឧបត្ថម្ភឱ្យស្នាក់នៅក្នុងគ្រួសារតាមរយៈការផ្តល់ការប្រឹក្សាយោបល់ដោះស្រាយបញ្ហាគ្រួសារ គាំទ្រអាជីវកម្មខ្នាតតូច សិប្បកម្មតាមផ្ទះ ការព្យាបាល មធ្យោបាយ ធ្វើដំណើរ អាហារ ទឹកដោះគោ និង ជួលផ្ទះឱ្យស្នាក់នៅនៅភ្នំពេញ និងបណ្តាញខេត្តនានា។ |
| | - តាមដានកុមារ និងយុវវ័យតាមផ្លូវ ២,៥00 នាក់បន្ថែមទៀត ដែលបានគាំទ្រពីមុនមក | - បានចុះសួរសុខទុក្ខកុមារ ១៣,៩៩៩ដង (ស្រី៥,៥0៤ដង) ដែលបានធ្វើជាមួយកុមារចំនួន ១,៧២៣នាក់ (ស្រី៧0៧នាក់) នៅគ្រួសារ កន្លែងធ្វើការរបស់ពួកគេ ដើម្បីតាមដានពីស្ថានភាពពួកគេនិងសុខុមាភាពបន្ទាប់ពីសមាហរកម្ម។ការសួរសុខទុក្ខធ្វើឡើងនៅបណ្តាលខេត្តនានាក្រោមកិច្ចសហការណ៍ពីមន្ទីរសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាខេត្ត។ |
| | - កុមារ/យុវវ័យតាមផ្លូវ ៥0 នាក់ក្នុងមួយ ឆ្នាំត្រូវបានចុះបញ្ជីផ្លូវច្បាប់/ធ្វើនីតិកម្ម (អត្តសញ្ញាណប័ណ្ណសំបុត្រកំណើតចុះឈ្មោះបោះឆ្នោត តាមការចាំបាច់)ក្នុងនាមជាពលរដ្ឋកម្ពុជាក្នុងមួយឆ្នាំនៅឆ្នាំ ២0១១ | - កុមារ/យុវវ័យចំនួន១៩នាក់(ស្រី១0នាក់)ទទួលបានអត្តសញ្ញាណប័ណ្ណ ១0នាក់(ស្រី៧ នាក់) សំបុត្រកំណើតដោយស្របច្បាប់ចំនួន ៥នាក់(ស្រី៣នាក់) និងចុះឈ្មោះបោះឆ្នោតចំនួន ៤នាក់។ |

| | | |
|---|---|---|
| ១.៤ ចូលរួមយ៉ាងខ្លាំងក្លាជាមួយសេវាកម្ម ដែលពាក់ព័ន្ធរបស់រដ្ឋាភិបាល/អាជ្ញាធរនៅក្នុងគម្រោង។ | - អាជ្ញាធរជាតិត្រូវបានទទួលជ្រាប និងចូលរួម យ៉ាងសកម្មនៅក្នុងកម្មវិធី | <u>ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា</u><br>– មិត្តសំឡាញ់បានចូលរួមប្រជុំជាប្រចាំត្រីមាសជាមួយក្រសួងសង្គមកិច្ចដើម្បីចែករំលែកព័ត៌មានអំពីករណី/សមាហរណកម្មកុមារ និងពង្រឹងកិច្ចសហការ រវាងអង្គការមិត្តសំឡាញ់ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។<br>– មិត្តសំឡាញ់បានចូលរួមសិក្ខាសាលាជាច្រើនរៀបចំដោយក្រសួងនិងមន្ទីរសង្គមកិច្ច ដើម្បីចែករំលែកបទពិសោធន៍ រៀបចំនីតិវិធី និងស្វែងរកដំណោះស្រាយពាក់ព័ន្ធទៅនឹងការស៊ីកូនចិញ្ចឹម ការគ្រប់គ្រង ការដំណើរការមណ្ឌលស្តារនីតិសម្បទា សមាហរណកម្ម និងការតាមដានកុមារងាយរងគ្រោះ ការជួញដូរកុមារនិងស្ត្រី ការថែរក្សាកុមារនៅមណ្ឌលស្នាក់នៅ និងការផ្លាស់ប្តូរទីកន្លែង។<br>– មន្ត្រីសង្គមកិច្ចចំនួន ២៥នាក់ មកពី ខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តបាត់ដំបងបានធ្វើការសហការជាមួយមិត្តសំឡាញ់លើការស្វែងរក ប៉ាន់ប្រមាណគ្រួសារ ការផ្សះផ្សារ សមាហរណកម្ម តាមដានធ្វើផែនការគ្រួសារនិងអាជីវកម្ម។ កិច្ចសហការនេះផ្តល់ឱកាសឱ្យមិត្តសំឡាញ់សំរាប់ពង្រឹងសមត្ថភាពបុគ្គលិកសង្គមកិច្ចខេត្តលើការធ្វើការជាមួយកុមារនៅតាមថ្នល់ និងងាយរងគ្រោះជាពិសេសប្រសិទ្ធិភាពនៃការធ្វើសមាហរណកម្មកុមារទៅខេត្ត។<br>– ប្រធានគម្រោងសមាហរណកម្ម និងអ្នកគ្រប់គ្រងករណី បានផ្តល់ការបណ្តុះបណ្តាលចំនួន ២ដងលើប្រព័ន្ធគ្រប់គ្រងករណី និងវិធីប្រើប្រាស់ទំរង់មិត្តសំឡាញ់ ដល់បុគ្គលិកសង្គមកិច្ចមកពីខេត្តបាត់ដំបង កំពង់ស្ពឺ និងខេត្តកណ្តាល នាថ្ងៃទី៦–៨ខែកញ្ញា ឆ្នាំ២០១០ និង ថ្ងៃទី២២–២៤ ខែកញ្ញា ឆ្នាំ២០១០ ។<br>–វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាចំនួន ៩៤ ពីជំនាញវិជ្ជាជីវៈ និងអាជីវកម្មខ្នាតតូចត្រូវបានចុះហត្ថ |

| | | |
|---|---|---|
| | | លេខាទទួលស្គាល់ដោយ ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាហើយបានចែកជូនដល់សិស្សទាំងអស់។<br>– នាយិកាកម្មវិធីបានផ្តល់បទបង្ហាញដល់ជនបង្គោលរបស់ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាចំនួន ៣ដង ស្តីពីបទបង្ហាញពីបទពិសោធន៍លើនីតិវិធីបណ្តឹង របស់កុមារនៅក្នុងមណ្ឌលនៅភ្នំពេញ កំពង់ស្ពឺ និងសៀមរាប។<br><br><u>ក្រសួងអប់រំ យុវជន និង កីឡា/ វិទ្យាស្ថានជាតិអប់រំ</u><br>– អ្នកបច្ចេកទេសអប់រំក្រៅប្រពន្ធ័បានកិច្ចសហការយ៉ាងជិតស្និតជាមួយវិទ្យាស្ថានជាតិអប់រំ និងការិយាល័យអប់រំក្រៅប្រពន្ធ័ ដើម្បីបង្កើតឧបករសិក្សា។ សៀវភៅឧបករណ៏សិក្សា ( Tool Box) បានរៀបចំរួចរាល់ ក្នុងនោះ មានសំភារៈអប់រំតាមរយៈប័ណ្ណរូបភាពសំរាប់គ្រូបង្រៀន ដើម្បីឆ្លើយតបក្នុងការសិក្សារបស់ កុមារទៅលើការរៀនអក្សរ គណិតវិទ្យា និងវិទ្យាសាស្ត្រ។ សរុបសកម្មភាពចំនួន ៦០ ដែលបានបង្កើតនៅក្នុងប័ណ្ណរូបភាពទៅលើ ៣ មុខវិជ្ជារួមមាន: អក្សរ ១៩ ប័ណ្ណរូបភាព គណិតវិទ្យា២៤ បណ្ណ័រូបភាព និង វិទ្យាសាស្ត្រ១៧ បណ្ណ័រូបភាព។ សៀវភៅឧបករណ៏សិក្សានេះត្រូវបានឯកភាពដោយក្រសួងអប់រំ យុវជន និងកីឡា នាថ្ងៃទី៦ ខែ តុលា ឆ្នាំ២០១០។<br>– មិត្តសំឡាញ់ បានចូលរួមកិច្ចពិភាក្សាពគ្រោះយោបល់លើរបាយការណ៏ស្រាវជ្រាវម៉ាប៉ារៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០។<br>– បានរៀបចំកិច្ចប្រជុំរវាងមិត្តសំឡាញ់ និងនាយកសាលា នាយករង គ្រូចំនួន ៣៧២នាក់ មកពីសាលារដ្ឋទាំងនៅភ្នំពេញ និងកំពង់ចាមចំនួន ៥៧សាលា។ គោលបំណងដើម្បីបង្កើនការទំនាក់ |

| | | |
|---|---|---|
| | | ទំនងការងារ ធ្វើសមាហរណកម្មកុមារទៅសាលារដ្ឋព្រមទាំងឱ្យពួកគាត់ស្គាល់ពីសកម្មភាពរបស់អង្គការមិត្តសំឡាញ់ រួមបញ្ចូលទាំងដំណើរការធ្វើសមាហរណកម្ម។<br>– វិញ្ញាបនប័ត្របញ្ជាក់៧១សន្លឹក ត្រូវបានចុះហត្ថលេខាទទួលស្គាល់ដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា ហើយបានចែកជូនដល់សិស្សដែលបានប្រឡងជាប់អក្ខរកម្ម ដោយជោគជ័យនៅក្នុងមជ្ឈមណ្ឌលវិជ្ជាជីវៈ។<br><br><u>ក្រសួងសុខាភិបាល/អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន/អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍</u><br>– អាជ្ញាប័ណ្ណកម្មវិធីម្ចុល/សឺរ៉ាំងនៃអង្គការមិត្តសំឡាញ់ ត្រូវបានផ្តល់សារជាថ្មីពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនទៅដល់អង្គការមិត្តសំឡាញ់ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។<br>– ការព្យាបាលឱសថជំនួសមេតាដូន (MMT) បានចាប់ផ្តើមនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០១០ នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ–សូវៀត ដំណើរការដោយក្រសួងសុខាភិបាល ជាមួយការគាំទ្រដោយ អង្គការសុខភាពពិភពលោក អង្គការសុខភាពគ្រួសារអន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ថ្មីៗ នេះ មាន យុវវ័យចំនួន៤ នាក់ នៅក្នុងសហគមន៍បានទទួលការព្យាបាលឱសថជំនួសមេតាដូន នៅមន្ទីរពេទ្យមិត្តភាពខ្មែរ–សូវៀត ហើយកំពុងសិក្សាជំនាញនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលនៃអង្គការមិត្តសំឡាញ់ ។<br>– បានចូលរួមប្រជុំប្រចាំត្រីមាសយ៉ាងទៀងទាត់ ជាមួយក្រុមការងារទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍ពាក់ព័ន្ធនឹងគ្រឿងញៀន (DHA) លើសពីនេះទៅទៀត អង្គការមិត្តសំឡាញ់ក៏ត្រូវបានគេបញ្ចូលជាសមាជិកសកម្មនៃ (DHA) ដឹកនាំដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងបានរៀបកិច្ចប្រជុំប្រចាំខែពាក់ព័ន្ធជាមួយការបង្កើតមុខ |

| | | |
|---|---|---|
| | - មន្ទីរខេត្តដែលពាក់ព័ន្ធ ត្រូវបានចូលរួមនៅក្នុងគម្រោងជាបន្តបន្ទាប់ | ងាររបស់ទីប្រឹក្សា សំរាប់ការត្រួតពិនិត្យ មើលលើផែនការណ៍យុទ្ធសាស្ត្រថ្នាក់ជាតិនៃក្រុមការងារទប់ស្កាក់មេរោគអេដស៍/ជម្ងឺអេសដ៏ពាក់ព័ន្ធនឹងគ្រឿងញៀនរបស់ក្រុម DHA ២០០៨–២០១០ និងការបង្កើតមុខងារសំរាប់អនុក្រុមការងារលើការតាមដាន និងវាយតម្លៃ និងអនុក្រុមការងារលើគ្រឿងញៀន និងមេរោគអេដស៍/ជម្ងឺអេដស៍ ក្នុងការថែរក្សាមាជិកក្រុម DHA មិនអោយដាច់ពីគ្នា។<br>– បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់សំរាប់ការព្យាបាលគ្រឿង ញៀនតាម សហគមន៍រៀបចំដោយ ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម អង្គការសុខភាពពិភពលោកUNAIDS និងអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០។<br>– បានចូលរួមកិច្ចពិភាក្សា លើការត្រួតពិនិត្យលើគោលនយោបាយថ្នាក់ជាតិ និងគោលការណ៍នៃកម្មវិធីកម្មវិធីម្ហុល/សុីរ៉ាំងរៀបចំដោយអង្គការសុខភាពពិភពលោក នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០១០។<br><u>កិច្ចសហការជាមួយអាជ្ញាធរក្នុងស្រុក អង្គការដៃគូ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត :</u><br>– មន្ត្រីគ្រួសារធម៌នៃអង្គការមិត្តសំឡាញ់បានរៀបចំកិច្ចប្រជុំ ក្រោមការគាំទ្រពីអង្គការមូលនិធិកុមារសហប្រជាជាតិ (UNICEF) ស្តីពីបណ្តាញគ្រួសារធម៌ជាមួយអង្គការដៃគូផ្សេងៗ ដើម្បីធ្វើឱ្យនីតិវិធី នៃគ្រួសារធម៌មានលក្ខណៈស្តង់ដារថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១០ និង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១០ នៅហ្រ្វេនឌ្សអ៊ិនធីណាសិនណល។<br>– អ្នកសម្របសម្រួលគ្រឿងញៀន ត្រូវបានចូលរួមធ្វើបទបង្ហាញស្តីពីចំណេះដឹងគ្រឿងញៀនដល់និស្សិតវិទ្យាស្ថានបច្ចេកវិទ្យាដល់និស្សិតចំនួន ៣០០ នាក់ នាថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១០។<br>– បានបណ្តុះបណ្តាលបុគ្គលិករដ្ឋាភិបាលចំនួន ៤៤នាក់ (ស្រី ២៩នាក់) ចំនួន៣វគ្គ មកពី១៧ សង្កាត់ក្នុង៥ខណ្ឌរាជធានីភ្នំពេញ ស្តីពីសុខភាពបន្តពូជ កាមរោគនិងមេរោគអេដស៍/ជម្ងឺអេដស៍ |

| | | |
|---|---|---|
| | | នាខែកក្កដា និងខែធ្នូ ឆ្នាំ២០១០។<br>- មន្ត្រីប៉ូលីសចំនួន ២៥៥ នាក់ មកពី ៣៨ ភូមិ ៩ សង្កាត់ បានធ្វើការ និងមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងាររបស់បុគ្គលិកមិត្តសំឡាញ់ បន្ទាប់ពីពួកគាត់បានយល់ពីគម្រោងសកម្មភាពរបស់អង្គការមិត្តសំឡាញ់។<br>- បុគ្គលិកចំនួន ៤នាក់ មកពីអង្គការសេវាសង្គមកិច្ចកម្ពុជា (SSC) បានទទួលការចែករំលែកបទពិសោធន៍គ្រឿងញៀន ទៅលើរបៀបធ្វើការឱ្យកាន់តែមានប្រសិទ្ធិភាពជាមួយអ្នកប្រើប្រាស់គ្រឿងញៀនរួមបញ្ចូលកម្មវិធីម្ជុល/សឺរ៉ាំងពីក្រុមការងារតាមផ្លូវរបស់អង្គការមិត្តសំឡាញ់ នាថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១០។<br>- បុគ្គលិកចំនួន ២ នាក់មកពីសមាគមន៍អភិវឌ្ឍន៍ស្ត្រីកម្ពុជា បានទទួលការចែករំលែកបទ ពិសោធន៍ទៅលើការធ្វើការជាមួយអ្នកប្រើប្រាស់គ្រឿងញៀន ជាពិសេសអ្នកប្រើប្រាស់គ្រឿងញៀន ដោយចាក់តាមសរសៃ ពីក្រុមគ្រឿងញៀនតាមផ្លូវនៃអង្គការមិត្តសំឡាញ់នាថ្ងៃទី១ ខែកក្កដាឆ្នាំ ២០១០។<br>- បានទទួលបុគ្គលិកសង្កាត់ចំនួន ២នាក់ (ស្រី ១នាក់) នៅសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ និងសង្កាត់គោករកា ខណ្ឌដង្កោរបានមកធ្វើការយ៉ាងជិតស្និតជាមួយគម្រោងតាមផ្លូវ ទាំងនៅក្នុងមណ្ឌល និងសហគមន៍។<br>- មន្ត្រីគ្រូសារធម៌បានរៀបចំកិច្ចប្រជុំបណ្តាញគ្រូសារធម៌ចំនួន ៤ ដងស្តីពីសំភារៈអប់រំអនាម័យ ដោយមានការចូលរួមពីមន្ត្រីមកពីក្រសួងសង្គមកិច្ច និងអង្គការដៃគូចំនួន ៧រួមមាន : អង្គការអភិវឌ្ឍន៍សង្គ្រោះសកលកម្ពុជា ហ្វ្រេនឲ្យអ៊ិនធើណាសិនណល ម៉ារីណុល កុមារីករាយ អង្គការទ្រទ្រង់ និងអភិវឌ្ឍន៍សុខភាពអ្នកក្រីក្រ អង្គការ ទស្សនៈពិភពលោក និងអង្គការហាការ។<br>- ប្រធានក្រុមសមាហរកម្ម និងអ្នកបណ្តុះបណ្តាលហ្វ្រេនឲ្យអ៊ិនធើណាសិនណលបានផ្តល់ការបណ្តុះ |

| | | |
|---|---|---|
| | | បណ្តុះបណ្តាលស្តីពីការធ្វើ សមាហរកម្ម និងរបៀបធ្វើការជាមួយគ្រួសារដល់បុគ្គលិក១០នាក់ មកពីអង្គការដែលធ្វើការ ជាមួយកុមារ នាថ្ងៃទី ៨-៩ ខែមិថុនា ឆ្នាំ២០១០ រួមមាន: អង្គការផ្ទះរបស់យើងអង្គការកុមារ កំព្រាក្នុងក្តីសង្ឃឹម អង្គការខ្មែរអភិវឌ្ឍន៍សេរីភាព អង្គការគ្រួសារថ្មី អង្គការអភិវឌ្ឍន៍កុមារ និងសហគមន៍ក្រីក្រ មជ្ឈមណ្ឌលថែទាំសុខភាពកុមារ អង្គការមូលនិធិសេចក្តីស្រលាញ់ដល់កុមារសមាគមក្តីសង្ឃឹមកម្ពុជា អង្គការកុមារគេហរង្សី និងអង្គការម៉ារីណុល។ |
| ១.៥.សម្របសម្រួលជាមួយនឹងដៃគូ FA និង CYTI ផ្សេងទៀត។ | - ការផ្លាស់ប្តូរបទពិសោធន៍ និងសហការជាមួយនឹង អង្គការកល្យាណមិត្ត (Kaliyan Mith) និងកម្មវិធី FA ផ្សេងទៀតប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព<br><br>- ប្រព័ន្ធសម្របសម្រួល និង បញ្ជូនមានដំណើរការជាមួយនឹងសមាជិកបណ្តាញCYTI ក្នុងប្រទេសកម្ពុជា និងអន្តរជាតិ | – បុគ្គលិកហ្វ្រេនឡអ៊ិនធើណាសិនណាលថៃ (ភឿនភឿន) ចំនួន៥នាក់ (ស្រី១នាក់) បានមកទស្សនកិច្ច និងចែករំលែកបទពិសោធន៍ជាមួយគំរោងតាមផ្លូវ នាថ្ងៃទី១១-១៥ ខែមករា ឆ្នាំ ២០១០។<br>– ដោយមានកិច្ចសហការល្អជាមួយសមាជិកបណ្តាញ CYTI សមាជិកចំនួន ០៦ នាក់ (ស្រី០១នាក់) មកពីអេហ្សីប បានមកទស្សនកិច្ចកម្មវិធីរួមមាន: អប់រំក្រៅប្រព័ន្ធ សកម្មភាពនៃការផលិតសៀវភៅឧបករណ៍សិក្សា និងសកម្មភាពតាមផ្លូវ និងថែមទាំងបានទៅទស្សនកិច្ចមណ្ឌលស្នាក់នៅបណ្តោះអាសន្ន នាខែមិថុនា ឆ្នាំ ២០១០។<br>– បុគ្គលិកក្រុមសិប្បកម្មតាមផ្ទះនៃអង្គការមិត្តសំឡាញ់ និងហ្វ្រេនឡអ៊ិនធើណាសិនណល បានទស្សនកិច្ចសិក្សាគម្រោង របស់ហ្វ្រេនឡអ៊ិន ធើណាសិនណល នៅទីក្រុងបាងកក ប្រទេសថៃ និងដើម្បីរកភាពនូវគំនិតថ្មីៗ និងទិញសំភារៈ វត្ថុធាតុដើមខ្នាតធំ។<br>– ប្រធានគម្រោងអប់រំ និងប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបានទស្សនកិច្ចគម្រោងកល្យានមិត្តនៅខេត្តសៀមរាប ដើម្បីទទួលបទពិសោធន៍ និងជំនាញគ្រប់គ្រង។ តាមរយៈការទស្សនកិច្ចនេះ យើងអាចកែសម្រួលកម្មវិធីសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាល ដើម្បីពង្រឹងគុណភាពនៃការ បង្រៀន និងសេវានាថ្ងៃទី ៨-៩ ខែ មេសា ឆ្នាំ២០១០។ |

| | | |
|---|---|---|
| | | – បុគ្គលិកកល្យានមិត្តសៀមរាបចំនួន ៣ នាក់ បានមកទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធសកម្មភាពធ្វើការជាមួយកុមារតាមផ្លូវ ទាំងនៅតាមផ្លូវ និងមណ្ឌល នៅអង្គការមិត្តសំឡាញ់ រាជធានីភ្នំពេញ នាខែសីហា និងខែធ្នូ ឆ្នាំ ២០១០។<br>– អង្គការមិត្តសំឡាញ់បានរៀបចំកិច្ចប្រជុំបណ្តាញអ្នកធ្វើការងារជាមួយកុមារតាមផ្លូវនៅកម្ពុជាចំនួន ៣ដង ស្តីពី លទ្ធផលគម្រងឯកសារកុមារតាមផ្លូវ២០០៨ និងបានត្រៀមសំរាប់ធ្វើការអង្កេតតពៀងទុកប្រចាំឆ្នាំនៅឆ្នាំបន្ទាប់។<br>– បានចូលរួមការប្រជុំប្រចាំត្រីមាសយ៉ាងទៀងទាត់ ជាមួយគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តការចែករំលែកបទពិសោធន៍ជាមួយសមាជិកដទៃទៀត។<br>–បានចូលរួមកិច្ចប្រជុំ ក្រុមការងារធ្វើការជាមួយអ្នកប្រើប្រាស់គ្រឿងញៀន រៀបចំដោយហ្វ្រេន្សអ៊ិនធីណាសិនណាលអស់រយៈពេល២ថ្ងៃ និងបានអញ្ជើញដើម្បីធ្វើបទបង្ហាញលើការទំនាក់ទំនងល្អរវាងដៃគូរ និងបណ្តាញCYTI នាថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១០។ |
| ***លទ្ធផលទី២: នៅឆ្នាំ ២០១១ ដៃគូបណ្តាញការពារ សុវត្ថិ ភាពកុមារ (ChildSafe Network ) ចំនួន ៧០០ នឹងការពារគាំទ្រដល់កុមារចំនួន ៥.០០០ នាក់ នៅក្នុងទីក្រុងភ្នំពេញនិងខេត្តកំពង់ចាម។*** | | |
| ២.១ កំណត់ និងបណ្តុះបណ្តាលសមាជិកការពារសុវត្ថិភាពកុមារ (ChildSafe ) ចំនួន៦០០ នាក់។ | - សមាជិកការពារសុវត្ថិភាពកុមារ (ChildSafe ) ចំនួន៦០០នាក់ ទទួលបានការ បណ្តុះបណ្តាលនិងវិញ្ញាប័នបត្រ នៅឆ្នាំ ២០១១ | – នៅឆ្នាំនេះ មានសមាជិកការពារសុវត្ថិភាពកុមារសរុប ៤៦៧នាក់ រួមបញ្ចូលសមាជិកថ្មី ៩៦នាក់ ទទួលបានការបណ្តុះបណ្តាល និងវិញ្ញាបនបត្រ។<br><br>**<u>សមាជិកភ្នំពេញ ៣៨៤នាក់</u>** <u>(ថ្មី ៧១ នាក់)</u><br>– ម៉ូតូឌុប:១៧៣ (ថ្មី៣៦នាក់)<br>– ម៉ូតូរ៉ឺម៉ក:១៦៧ (ថ្មី៣៥នាក់) |

| | | |
|---|---|---|
| | - សមាជិកទាំងអស់ នឹងទទួលបានការបណ្តុះបណ្តាលឡើងវិញជារៀងរាល់ឆ្នាំ<br><br>- សមាជិកទាំងអស់ត្រូវបានវាយតម្លៃ និងតាមដានជាបន្តបន្ទាប់ | – តាក់ស៊ី: ០៤<br>**<u>សមាជិកកំពង់ចាម ១២៣នាក់</u>** <u>(ថ្មី ២៥នាក់)</u><br>– ម៉ូតូឌុប: ១០២(ថ្មី២៣នាក់)<br>– ម៉ូតូរ៉ឺម៉ក: ២១នាក់ (ថ្មី ០២ នាក់)<br>ក្នុងឆ្នាំនេះ សមាជិកសុវត្ថិភាពចំនួន ១១០នាក់ បានលុបឈ្មោះចេញពីបញ្ជីសមាជិកសុវត្ថិភាពកុមារ នៅភ្នំពេញ និងកំពង់ចាម ដោយសារតែ: ផ្លាស់ប្តូរមុខរបរ និងត្រឡប់ទៅស្រុកកំណើត។<br>– ៦០នាក់ ជាអ្នករត់ម៉ូតូឌុប នៅភ្នំពេញ<br>– ៤៨ នាក់ ជាអ្នករត់ម៉ូតូរ៉ឺម៉ក នៅភ្នំពេញ<br>– ០២ នាក់ ជាអ្នករត់ម៉ូតូឌុប នៅកំពង់ចាម<br>– សមាជិកសុវត្ថិភាពកុមារទាំងអស់ ទទួលបានការបណ្តុះបណ្តាល និងរំលឹកមេរៀនឡើងវិញលើប្រធានបទដូចជា: សុវត្ថិភាពកុមារ ចំណាកស្រុកមានសុវត្ថិភាព ផ្លូវសុវត្ថិភាពផលលំបាកនៃការផឹកគ្រឿងស្រវឹង លេងល្បែង និងបានផ្តល់ព័ត៌មានស្តីពីគ្រឿងញៀន បំណិនជីវិត និងសង្គ្រោះបឋម។<br>– សមាជិកសុវត្ថិភាពកុមារ ៤៦៧នាក់ ត្រូវបានតាមដាននិងវាយតម្លៃជាបន្តបន្ទាប់ក្នុងឆ្នាំនេះ។ |
| ២.២ កំណត់ និងបណ្តុះបណ្តាល ដៃគូការពារសុវត្ថិភាពកុមារ (ChildSafe ) ចំនួន១០០នាក់ | - ដៃគូការពារសុវត្ថិភាពកុមារ (ChildSafe ) ចំនួន ១០០ នាក់ ទទួលបានការបណ្តុះបណ្តាលនិងវិញ្ញាបនប័ត្រនៅឆ្នាំ២០១១<br><br>- ដៃគូទាំងអស់ទទួលបានការបណ្តុះ | – បុគ្គលិកធនាគារ ANZ Bank Royal ចំនួន ១៩៦នាក់ (ថ្មី ៣៣នាក់) ទទួលបានការបណ្តុះបណ្តាល និងវិញ្ញាបនបត្រដើម្បីក្លាយជាដៃគូការពារសុវត្ថិភាពកុមារ ។<br>– ការវាយតម្លៃលើគម្រោងសុវត្ថិភាពកុមារ បានធ្វើឡើងដោយអ្នកវាយតម្លៃខាងក្រៅនៅក្នុងខែមីនា ឆ្នាំ២០១០ ។លទ្ធផលនិងអនុស្សាសន៍សំខាន់ៗរួមមាន: |

| | | |
|---|---|---|
| | បណ្តាលឡើងវិញជារៀងរាល់ឆ្នាំ<br>- ដៃគូទាំងអស់ត្រូវបានវាយតម្លៃ និងតាមដានជាបន្តបន្ទាប់ | – សម្របសម្រួលជាមួយសមាជិក និងដឹងពីពេលវេលាជាក់លាក់នៅពេលករណីមានការកើនឡើង នៅតាមតំបន់នីមួយៗ<br>– បង្កើនការប្រជុំសមាជិកឱ្យបានញឹកញាប់ដើម្បីពង្រឹងទំនាក់ទំនងរវាងសមាជិក និងអារម្មណ៍របស់សមាជិក<br>– បង្កើនការយល់ដឹងតាមរយៈសម្ភារៈអប់រំជាភាសាខ្មែររួមមាន ផ្ទាំងរូបភាព ស្ទិកឌ័រ និងអាវភ្លៀង។ល។ |
| ២.៣ គាំទ្រដល់សមាជិក និងដៃគូការពារសុវត្ថិភាពកុមារ (ChildSafe) ដើម្បីផ្តល់ការការពារដល់កុមារចំនួន ៥.០០០ នាក់។ | - កុមារចំនួន ១.០០០នាក់ ទទួលបានការបញ្ជូននៅ ឆ្នាំ ២០១១<br>- កុមារចំនួន ៥.០០០នាក់ ទទួលបានការការពារនៅឆ្នាំ ២០១១<br><br>- មណ្ឌលការពារសុវត្ថិភាពកុមារ (ChildSafe) នៅក្នុងទីក្រុងភ្នំពេញត្រូវបានប្រតិបត្តិដោយអង្គការមិត្តសំឡាញ់នៅឆ្នាំ២០១១ | - កុមារចំនួន៣,២៣៥ (ស្រី១១៧១នាក់) ទទួលបានការគាំទ្រនិងការពារដោយបណ្តាញសុវត្ថិភាពកុមារ នៅភ្នំពេញ និងកំពង់ចាម។<br>- កុមារចំនួន ៤៤០ (ស្រី១៧៥នាក់) បានបញ្ជូនដោយសមាជិកសុវត្ថិភាពកុមារនៅភ្នំពេញ និងកំពង់ចាម។<br>- កុមារចំនួន ២,៧៩៥នាក់ (ស្រី៩៩៦នាក់) ទទួលបានព័ត៌មានស្តីពីការការពារខ្លួនអោយមានសុវត្ថិភាព។<br>- អង្គការមិត្តសំឡាញ់មានកិច្ចសហការជាមួយជាមួយមណ្ឌលសុវត្ថិភាពកុមារនៃអង្គការហ្វ្រេនអ៊ិនធឺណាស៊ិនណល |
| ២.៤ ចូលរួមផ្សព្វផ្សាយយុទ្ធនាការអន្តរជាតិ ស្តីពីការពារសុវត្ថិភាពកុមារនៅក្នុងទីក្រុងភ្នំពេញ(សម្រាប់អ្នក | - យុទ្ធនាការអន្តរជាតិស្តីពី បញ្ឈប់ការអោយលុយទៅកុមារតាមថ្នល់ ត្រូវបានសម្ពោធ និងអនុវត្តនៅក្នុងទីក្រុងភ្នំពេញនៅដើមត្រីមាសទី២ នៃ ឆ្នាំ ២០០៨ | - យុទ្ធនាការអន្តរជាតិស្តីពីបញ្ឈប់ការអោយលុយទៅកុមារតាមថ្នល់បានធ្វើតាំងពីឆ្នាំ២០០៨។<br><br>- ខិតបណ្ណ័ណែនាំ ៧ចំណុច សំរាប់អ្នកធ្វើដំណើរបានចាប់ផ្តើប្រើប្រាស់តាំងពីឆ្នាំ២០០៨ ហើយឥឡូវ |

| | | |
|---|---|---|
| ទេសចរ) ដែលផ្តោតគោលដៅចំពោះអ្នកទេសចរណ៏អន្តរជាតិចំនួន៣០%ដែលមកកាន់ទីក្រុងភ្នំពេញក្នុងមួយឆ្នាំៗ។ | - យុទ្ធនាការផ្សព្វផ្សាយដល់អ្នកទេសចរណ៏ត្រូវបានអនុវត្តនៅក្នុងទីក្រុងភ្នំពេញនៅត្រីមាសទី៤នៃឆ្នាំ២០០៨<br>- អ្នកទេសចរមកទីក្រុងភ្នំពេញចំនួន ៣០%ក្នុងមួយឆ្នាំទទួលបានការអប់រំផ្សព្វផ្សាយ | នេះយើងបានបកប្រែជាភាសា៣ ភាសារួមភាសាបារាំង ជប៉ុន និងចិន។ |
| ***លទ្ធផលទី៣: នៅឆ្នាំ ២០១១ គម្រោងមាននិរន្តភាព ៦០% តាមរយៈការបង្កើតកម្មវិធីអាជីវកម្មតាមរយៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងអាជីវកម្មសង្គម។*** | | |
| ៣.១ ការបង្កើតការបណ្តុះបណ្តាលអាជីវកម្ម | - ភោជនីយដ្ឋានចំនួន ៣ មានដំណើរការ<br>- ការបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់មានមុខងារជាអាជីវកម្មនៅឆ្នាំ ២០១១ | ថ្នាក់ចុងភៅចំនួន ៣ កំពុងដំណើរការធ្វើជំនួញនាពេលបច្ចុប្បន្ននេះ រួមមានៈ ឡឺកាហ្វេមិត្តសំឡាញ់ ថ្នាក់ចុងភៅកំរិត២ (រំដេង) និងថ្នាក់ចុងភៅកំរិត៣ (ហ្រ្វេន្ស) ។<br>- **ឡឺ កាហ្វេមិត្តសំឡាញ់** ស្ថិតនៅក្នុងសួនច្បារដ៏ឆើតឆាយនៃមជ្ឈមណ្ឌលវប្បធម៌បារាំង ជាថ្នាក់បណ្តុះបណ្តាល មានបំរើសេវាកម្មអាហារពេលព្រឹក អាហារថ្ងៃត្រង់ប៊ូហ្វេខ្មែរ និងទទួលរៀបចំសំរាប់ព្រឹត្តិការណ៏ផ្សេងៗ នាពេលល្ងាច។ ភោជនីដ្ឋានបណ្តុះបណ្តាលនេះ ស្វាគមន៏សំរាប់សិស្សកំរិតមួយ លើសេវាចំអិន ដើម្បីទទួលបានបទពិសោធន៏ជាអាជីពជាមូលដ្ឋាន និងការទំនាក់ទំនងជាមួយ អតិថិជន លើសេវាអាហារប្រភេទប៊ូហ្វេ ។<br>- **ថ្នាក់ចុងភៅរំដេង** គឺជាថ្នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្នែកចុងភៅកំរិត២ មានបំរើជាលក្ខណះម្ហូបបែបខ្មែរ មានអាហារពិសេសប្រចាំសប្តាហ៏និងមានជាអាហារឈុតសំរាប់ផ្តល់ជូនអតិថិជនជារៀងរាល់ថ្ងៃ។ ជាមធ្យមក្នុងមួយខែ ភោជនីយដ្ឋានរំដេងមានសិស្សចំនួន ៣០នាក់ បានទទួលវគ្គបណ្តុះបណ្តាល ហើយក្នុងនោះក៏មានសិស្សចំនួន ០៩នាក់ ដែលចេញទៅធ្វើការងារបាន |

| | | |
|---|---|---|
| | | ដោយខ្លួនឯង។ នៅក្នុងឆ្នាំនេះសិស្សសរុប ៦៤នាក់ (ស្រី១៣នាក់) បានទទួលវគ្គបណ្តុះបណ្តាលផ្នែកខាងសេវាកម្ម និងការចំអិនម្ហូបនៃគម្រោងរបស់មិត្តសំឡាញ់។ សិស្សសរុបចំនួន១៥នាក់ បានបញ្ចប់នៅថ្នាក់ចុងភៅរ៉ដេង ហើយកំពុងបន្តរៀននៅថ្នាក់ចុងភៅ ហ្វ្រេន្ឌស៍។<br>- **ថ្នាក់ចុងភៅ ហ្វ្រេន្ឌស៍** គឺជាថ្នាក់ចុងភៅកំរិត៣ មានបំរើនូវម្ហូបបែបអាស៊ីនិងអឺរ៉ុបជាលក្ខណៈ ចានតូច ហើយក៏មានម្ហូបពិសេសប្រចាំ សប្តាហ៍បែបចានធំផងដែរ ដោយមានការផ្លាស់ប្តូរ និងបង្ហាញពីរបៀបផ្តល់សេវាកម្មជូនអតិថិជន និងវិធីសាស្រ្តនៃការបង្រៀនសិស្សផងដែរ។ ជាមធ្យម ភោជនីយដ្ឋានហ្វ្រេន្ឌស៍ផ្តល់វគ្គបណ្តុះបណ្តាលដល់សិស្សចំនួន ២៨នាក់។ សិស្សសរុប ៤៦នាក់ (ស្រី៩នាក់) បានទទួលវគ្គបណ្តុះបណ្តាលផ្នែកខាងសេវាកម្ម និងការចំអិនម្ហូបនៃគំរោងរបស់មិត្តសំឡាញ់ ។<br>- ការធ្វើក្រចក (ថ្នាក់សំអាង) គឺជាថ្នាក់បណ្តុះបណ្តាលអាជីវកម្ម មានទីតាំងនៅក្នុងហាងហ្វ្រេន្ឌស៍អេនស្តាហ្វ ជិតភោជនីយដ្ឋានហ្វ្រេន្ឌស៍។ សិស្សទាំងនោះ មកពីថ្នាក់សំអាងនៃអង្គការមិត្តសំឡាញ់ដែលផ្តល់ឱកាសឱ្យធ្វើការក្នុងកំឡុងពេលសិក្សា និងទទួលបានបទពិសោធន៍បន្ថែម ខណៈពេលរង់ចាំការធ្វើសមាហរកម្ម។<br><br>ថ្នាក់សំអាងទទួលបានប្រាក់ចំណូលសរុបចំនួន១២,១៥៨.២៥ ដុល្លារ និងប្រាក់ចំណេញ ៥,២១៦.៥៩ ដុល្លារ។ |
| | - អាជីវកម្មតាមរយៈ ផ្តល់ការបណ្តុះបណ្តាលទាំង អស់អាចផ្តល់ប្រាក់ចំណេញបន្ទាប់ពីដំណើរការបាន ១៨ខែ | - មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មានមុខវិជ្ជាផ្សេងៗទៀតក៏បានរកប្រាក់ចំណូលផងដែរ រួមមានៈ កាត់ដេរ ជួសជុលម៉ូតូ ជួសជុលឡាន អគ្គិសនី អេឡិចត្រូនិច បោកគក់ ផ្សារដែក កសិកម្ម ចុងភៅកំរិត១ កាត់សក់ និងថ្នាក់សំអាង ។ ប្រាក់ចំណូលសរុបចំនួន ២៣,៨៣០.៨៥ ដុល្លារ |

| | | |
|---|---|---|
| | - ចូលរួមផ្តល់ថវិកា ៦០%នៃផលចំណេញសរុប | និងប្រាក់ចំណេញសរុបចំនួន ៦,០៨៥.៦០ដុល្លារ។<br>- អាជីវកម្មតាមរយៈការបណ្តុះបណ្តាលទាំងអស់ អាចទទួលបានប្រាក់ណូល ៨៧៩,៤៣១.១០ ដុល្លារ និងចំណេញ ១៩៥,៥០៧.៤០ ដុល្លារបានមកពីថ្នាក់ចុងភៅ/ដេរ ប្រហ្វេន្ស និងថ្នាក់ធ្វើ ក្រចក និងថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់។<br>- អាជីវកម្មតាមរយៈការបណ្តុះបណ្តាលទាំងអស់ បានចូលរួមផ្តល់ថវិកា៣៣%នៃប្រាក់ចំណូលសរុប។ |
| ៣.២ ការបង្កើតអាជីវកម្មផ្នែកសង្គមកិច្ច | - ការស្រាវជ្រាវទីផ្សារត្រូវបានអនុវត្តនៅឆ្នាំ២០០៩<br><br>- អាជីវកម្មសង្គមចំនួន២ ត្រូវបានបង្កើតឡើងនៅ ឆ្នាំ ២០១១ | - ការស្រាវជ្រាវទីផ្សារអាជីវកម្មខ្នាតតូច បានធ្វើឡើងដោយមិត្តសំឡាញ់ និងហ្វ្រេនអ៊ិនធើណាសិនណល នៅត្រីមាសទី១ឆ្នាំ២០១០ តាមរយៈការ សម្ភាសន៍អ្នកធ្វើអាជីវកម្មខ្នាតតូចចំនួន ៣៣ នាក់នៅភ្នំពេញ។ ជាលទ្ធផល កម្មវិធីសិក្សាអាជីវកម្មខ្នាតតូច ត្រូវបានបង្កើតឡើងសំរាប់បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់ក្រុមគោលដៅ ដើម្បីចាប់ផ្តើមអាជីកម្មប្រកបដោយនិរន្តភាព។<br>- អាជីវកម្មសង្គម ត្រូវបានបង្កើតឡើងនៅភ្នំពេញ និងកំពង់ចាមដើម្បីគាំទ្រ គ្រួសារឱ្យទទួលបានជំនាញ និងបង្កើនប្រាក់ចំណូលសមរម្យ និងទៀងទាត់ ដូច្នេះកុមារមិនចាំបាច់ទៅធ្វើការ ហើយអាចចូលសាលារៀនបាន ។<br><br>ក្នុងឆ្នាំនេះ មានអ្នកចូលរួមចំនួន១០៧នាក់ បានចូលរួមក្នុងគម្រោងអាជីវកម្មសង្គមនៅភ្នំពេញ។ អ្នកចូលរួមអាចទទួលបានប្រាក់ចំណូលជាមធ្យមចំនួន ៩២ ដុល្លារ/ក្នុង១ ខែ នៅភ្នំពេញ។ លើសពីនេះទៀត ពាក់កណ្តាលនៃអ្នកផលិត បានបង្កើតផលិតផលនៅអង្គការហ្វ្រេនអ៊ិនធើណាសិនណលសម្រាប់ការកម្មង់ពិសេស ដែលអាចធ្វើឱ្យពួកគេទទួលបានជំនាញកំរិតខ្ពស់ និងបង្កើនប្រាក់ចំណូលរបស់ពួកគេ។ |

| | | |
|---|---|---|
| | | – ផ្នែកបោះពុម្ភកំពុងដំណើរការចាប់តាំងពី ឆ្នាំ២០១០ និងទទួលការបញ្ជាទិញជាច្រើនពីខាងក្នុង និង ខាងក្រៅ ដែលអាចផ្តល់ការងារឱ្យអាណាព្យាបាលចំនួន ១១នាក់ (ស្រី០៧នាក់)សំរាប់រយៈខ្លីមួយ។<br>– ក្រុមសិប្បកម្មតាមផ្ទះបានចូលរួមព្រឹត្តិការណ៍ផ្សេងៗ និង ពិព័ណ៌ Fun Fair ដើម្បីផ្សព្វផ្សាយពីផលិតផលដល់សាធារណជនរួមមាន: ពិព័ណ៌បែតង់នៅសាលាអន្តរជាតិភ្នំពេញ ពិធីបុណ្យណូអែលរបស់ក្រុមហ៊ុនប៊ីឡាញ ។<br>– ផលិតផល ៣២ មុខត្រូវបានបង្កើត និងផលិតសំរាប់ការលក់នៅក្នុង និងក្រៅស្រុក ។ អតិថិជនក្រៅស្រុករួមមាន: អ៊ឺរ៉ុប អូស្ត្រាលី សាំងហ្គាពួរ កាន់ណាដា និងអាមេរិច តាមរយៈហ្វ្រេន្ទអ៊ិនធឺណាសិនណល។ |
| | - អាជីវកម្មផ្នែកសង្គមកិច្ច ទាំងអស់ផ្តល់ប្រាក់ចំណេញបន្ទាប់ពីដំណើរការបាន១២ ខែ | - អាជីវកម្មផ្នែកសង្គមកិច្ចទទួលបានប្រាក់ចំណូល ១០៤,៧៩៦.៣២ដុល្លារ និងប្រាក់ចំណេញ ១៨,៣៦០.៩៦ ដុល្លារ។ |
| | - ចូលរួមវិភាគទាន៣០%នៃប្រាក់ចំណេញសរុប | - អាជីវកម្មផ្នែកសង្គមកិច្ចបានចូលរួមផ្តល់ថវិកា ៤% នៃប្រាក់ចំណូលសរុប។ |
| ៣.៣ ការបង្កើតសេវាកម្ម និងផលិតផលរកប្រាក់ចំណូល | - ផលិតផលត្រូវបានរចនាម៉ូត ជាបន្តបន្ទាប់ (សរុប១០មុខនៅឆ្នាំ២០១១ | - **ហាងលក់ទំនិញហ្វ្រេន្ទអេនស្តាហ្វ** ស្ថិតនៅជិតភោជនីដ្ឋានហ្វ្រេន្ទ មានលក់សៀវភៅចាស់ៗ សំលៀកបំពាក់ និងផលិតផលដែលធ្វើដោយ:<br>– អ្នកផលិតក្នុងគំរោងសិប្បកម្មតាមផ្ទះ មាននៅប្រទេសកម្ពុជានិងឡាវ<br>– យុវវ័យក្នុងថ្នាក់ជំនាញវិជ្ជាជីវៈ នៃអង្គការមិត្តសំឡាញ់ |

| | | |
|---|---|---|
| | - ចូលរួមផ្តល់ថវិកា១០%នៃប្រាក់ចំណេញសរុប | –សំភារៈឧបត្ថម្ភដទៃផ្សេងទៀត<br>–ផលិតផលមកពី អង្គការដទៃ ទៀតរួមមាន: វិចិត្រសាលគំនូរីករាយ សមាគមន៍សង្គ្រោះសត្វដីរភ្នំតាម៉ៅ ដីរស សង្គ្រោះសត្វព្រៃនៅកម្ពុជា ស៊ីប៉ា អប៉ំរពិភពលោក អង្គការស្ត្រីផ្ទុកមេរោគអេដស៍ រោងចក្រ ថ្នៃម៉ូថទំនើប។<br>–សំលៀកបំពាក់ និងឧបករណ៍ផ្សេងៗពីហាង ២៤០ នៃអង្គការប្រ្វេន្សអ៊ិនធើណាសិនណល<br>–បានចុះកុងត្រាជាមួយកន្លែងផ្ញើរលក់ចំនួន១២រួមមាន: អង្គការកម្ពុជាជួយជនរងគ្រោះដោយទឹកអាស៊ីត អង្គការស អង្គការដំណក់ទឹកប៉ោយប៉ែត អង្គការដីរស អង្គការអូស្មូសអង្គការសង្គ្រោះសត្វព្រៃនៅកម្ពុជា ស៊ីប៉ា ម្លប់តាប៉ាង សមាគមន៍ចាស់ជរាខេត្តតាកែវ សង្គ្រោះសត្វដីរភ្នំតាម៉ៅ បឹងឈូក និងវិចិត្រសាលគំនូរីករាយ។<br><br>- **សៀវភៅធ្វើម្ហូប** ត្រូវបានផលិតតាំងពី ខែធ្នូ ឆ្នាំ ២០០៤ អាចរកទិញបាននៅភោជនីដ្ឋានប្រ្វេន្សរំដេង ហាងលក់ទំនិញប្រ្វេន្ស អេន ស្តាហ្វ ហាងទូចទូច ហាង ២៤០ បណ្ណាគារ Monument Books និងនាំចេញទៅប្រទេសអង់គ្លេស និងកន្លែងផ្ញើរលក់ទាំង នៅភ្នំពេញនិងសៀមរាប សំរាប់បង្កើនប្រាក់ចំនូលដល់អង្គការ។ ទទួលបានប្រាក់ចំណូល ៤៣,៤៤៦.៤០ដុល្លារ និងចំណេញ ២៤,០៩១.៧៥ ដុល្លារ ។<br>- ចូលរួមផ្តល់ថវិកា ៧ % នៃប្រាក់ចំណូលសរុប។ |
| ***លទ្ធផលទី៤: នៅឆ្នាំ ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh ) ត្រូវបានទទួលស្គាល់ថាជាអង្គការមាន ប្រព័ន្ធរដ្ឋបាលល្អបំផុត។*** | | |
| ៤.១ បង្កើតការិយាល័យ | - SoP របស់ប្រព័ន្ធគណនេយ្យ ត្រូវបាន | - បទដ្ឋាននៃនីតិវិធីនៃប្រព័ន្ធគណនេយ្យកំពុងពង្រាងនៅឡើយដោយការគាំទ្រពីប្រ្វេន្សអ៊ិនធើណា |

| | | |
|---|---|---|
| គណនេយ្យ ប្រកបទៅដោយប្រសិទ្ធភាព ទាន់ពេលវេលា និងមានដំណើរការយ៉ាងមានតម្លាភាព ពេញលេញ។ | អនុវត្តនៅត្រីមាសទី៤ នៃឆ្នាំ២០០៨<br>- សវនកម្មធ្វើឡើងទាន់ពេលវេលា និងមានលក្ខណៈវិជ្ជមាន<br>- របាយការណ៍គណនេយ្យ ត្រូវបានផ្ញើជូនទៅគណៈគ្រប់គ្រងនិងក្រុមការងារជារៀងរាល់ខែ | សិនណេល។<br>- របាយការណ៍សវនកម្មឆ្នាំ២០០៩របស់អង្គការមិត្តសំឡាញ់ បានបញ្ចប់ហើយសវនកម្មសំរាប់ឆ្នាំ ២០១០ នឹងចាប់ផ្តើម នៅខែមីនា ឆ្នាំ២០១១។<br>- ក្រុមគណនេយ្យបានកែសំរួលរចនាសម្ពន្ធ័ និងធ្វើឱ្យប្រសើរឡើងដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ម្ចាស់មូលនិធិឱ្យទាន់ពេលវេលា។ |
| ៤.២ កសាងផ្នែកគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាពក្នុងការគាំទ្រដើម្បីអោយការអនុវត្តន៍សេវាកម្មបានល្អដែល ទទួលស្គាល់ថាជាការអនុវត្តន៍ ល្អបំផុត។ | - SoP របស់ប្រព័ន្ធរដ្ឋបាលត្រូវបានអនុវត្តនៅត្រីមាសទី៤ នៃឆ្នាំ ២០០៨<br>- SoP របស់ប្រព័ន្ធធនធានមនុស្សត្រូវបានអនុវត្តនៅត្រីមាសទី៤នៃឆ្នាំ២០០៨<br>- រាល់ការទំនាក់ទំនង (ខាងក្នុង និងខាងក្រៅ) ត្រូវបានដំណើរការប្រកបដោយប្រសិទ្ធិភាព<br>- ការទំនាក់ទំនងជាមួយនឹង FA និង CYTI ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព<br>- CCC នឹងរក្សាវិញ្ញាបនបត្រលើការប្រតិ | - បទបញ្ជាផ្ទៃក្នុងរបស់អង្គការមិត្តសំឡាញ់ បានបញ្ចប់ដោយមានការគាំទ្រពីហ្វ្រេនអ៊ិនធើណាសិនណេល និងឯកភាពពីសមាជិកក្រុមប្រឹក្សាភិបាល បន្ទាប់មកបានធ្វើបទបង្ហាញជូនដល់ប្រធានក្រុមអ្នកគ្រប់គ្រប់គំរោង និងគណៈគ្រប់គ្រង់ទាំងអស់ក្នុងឆ្នាំនេះ។<br>- បទដ្ឋាននៃនីតិវិធីរបស់ប្រព័ន្ធធនធានមនុស្ស បានកែសំរួលសម្រាប់ការជ្រើសរើស និងការវាយតម្លៃបុគ្គលិក។<br>- តាមរយៈកិច្ចសហការពីមន្រ្តីផ្នែកទំនាក់ទំនង ហ្វ្រេនអ៊ិនធើណាសិនណេល អង្គការមិត្តសំឡាញ់ត្រូវបានទទួលស្គាល់ច្រើនតាមរយៈសារព័ត៌មានសំខាន់ៗ ក៏ដូចជាការមកធ្វើទស្សនកិច្ចពីភ្ញៀវទេសចរណ៏នានា។<br>- ការទំនាក់ទំនងរវាងហ្វ្រេនអ៊ិនធើណាសិនណេល និងមិត្តសំឡាញ់ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាពដើម្បីធានាកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល។<br>- អង្គការមិត្តសំឡាញ់ បានដាក់ពាក្យសុំឡើងវិញសំរាប់ប្រព័ន្ធវិញ្ញាបនបត្រដែលមានលក្ខណៈស្ម័គ្រចិត្ត |

| | | |
|---|---|---|
| | បត្តិល្អចំពោះអង្គការGPP | នៅក្នុងគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាល (NGO-GPP) នាថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០១០ ហើយលទ្ធផលនឹងដឹងនាពេលឆាប់ៗនេះ។ |
| ៤.៣ គណៈគ្រប់គ្រងរបស់អង្គការមិត្តសំឡាញ់ (Mith Samlanh) ផ្តល់នូវការគាំទ្រជាបន្តបន្ទាប់ដល់ក្រុមការងារ។ | - របនាសម្ព័ន្ធគ្រប់គ្រងទូទៅ ត្រូវបានអនុវត្ត នៅត្រីមាសទី៤នៃឆ្នាំ២០០៨<br>- ការផ្តល់យោបល់/ការវាយតម្លៃពីក្រុមអង្គការមិត្តសំឡាញ់ (Mith Samlanh) មាន លក្ខណៈវិជ្ជមាន | - របនាសម្ពន្ធ័នៃអង្គការមិត្តសំឡាញ់ត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់តាំងពីឆ្នាំ២០០៩។ តំបន់មួយបានធ្វើការប៉ាន់ប្រមាណតាំងពីឆ្នាំ២០១១ ដើម្បីប្រាកដថាអ្នកឯកទេសអាចផ្តល់ការគាំទ្រដល់ក្រុមពាក់ព័ន្ធបាន។<br>- គណៈគ្រប់គ្រងអង្គការមិត្តសំឡាញ់មានការបារម្ភលើការលើកទឹកចិត្តក្រុមការងារ និងប្រាថ្នាចង់ដោះស្រាយស្ថានភាពនេះនៅឆ្នាំ២០១១។ |
| ៤.៤ ក្រុមប្រឹក្សាភិបាលរបស់អង្គការមិត្តសំឡាញ់ (Mith Samlanh Board) ផ្តល់ការគាំទ្រ ជាវិជ្ជមានដល់អង្គការ និងការគ្រប់គ្រងរបស់អង្គការ។ | - កិច្ចប្រជុំមានការចូលរួមយ៉ាងល្អ និងទៀងទាត់<br>- ក្រុមប្រឹក្សាភិបាលផ្តល់ការគាំទ្រដូចមានចែងក្នុងលក្ខន្តិកៈ | - នៅក្នុងឆ្នាំនេះ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលបានធ្វើឡើងចំនួន២ដង ដើម្បីបង្ហាញពីសមិទ្ធិផលការងារ របស់អង្គការមិត្តសំឡាញ់ប្រចាំឆមាសក្នុងឆ្នាំ២០១០ ដំណើរការគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាល (NGO-GPP) សំរាប់ប្រព័ន្ធវិញ្ញាបនបត្រដែលមានលក្ខណៈស្ម័គ្រចិត្ត ឯកភាពលើបទបញ្ជាផ្ទៃក្នុងរបស់អង្គការមិត្តសំឡាញ់ និងបានពិភាក្សាសំរេចលើផែនការយុទ្ធ សាស្ត្រ។ |
| ***លទ្ធផលទី៥: នៅឆ្នាំ ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh) ទទួលបានកម្មសិទ្ធិទាំងស្រុងលើអចលនទ្រព្យ (TC/EC) និងបានសាងសង់មជ្ឈមណ្ឌល ដែលផ្តល់នូវបរិយាកាសប្រកបដោយ គុណភាព សម្រាប់ការងាររបស់ខ្លួន។*** | | |
| ៥.១ អង្គការមិត្តសំឡាញ់ (Mith Samlanh) បង្កើត របនាសម្ព័ន្ធច្បាប់ (កាន់កាប់ | - របនាសម្ព័ន្ធច្បាប់បានបង្កើត ឡើងនៅត្រីមាសទី៤ នៃឆ្នាំ ២០០៨ | - របនាសម្ព័ន្ធច្បាប់បានបង្កើតរួចហើយតាំងពីឆ្នាំ២០០៩។ |

| | | |
|---|---|---|
| ក្រុមហ៊ុន | | |
| ៥.២ អង្គការមិត្តសំឡាញ់ (MithSamlanh )សងប្រាក់កម្ចីធនាគារ | - ការរៃអង្គាសមូលនិធិប្រព្រឹត្តទៅដោយប្រសិទ្ធភាព<br>- ការសងប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព នៅមុនកាលកំណត់របស់ធនាគារ | - ប្រាក់សុរបចំនួន ២០,១៥២ ដុល្លារ បានមកពីយុទ្ធនាការលក់ដុំឥដ្ឋនិងកម្មវិធី Fun Fair ហើយចំរិការទាំងអស់ត្រូវបានបែងចែកលើការទិញដីនៃអង្គការមិត្តសំឡាញ់។អង្គការមិត្តសំឡាញ់បានទូរទាត់សងធនាគារ ANZ Royal រួចរាល់អស់ហើយ តាមរយៈការផ្តល់កម្ចីពីម្ចាស់មូលនិធិ។ នៅថ្ងៃទី៣១ ខែធ្នូ មិត្តសំឡាញ់នៅមានសមតុល្យនៃប្រាក់កម្ចីស្មើរនឹង ២៤៦,១៦២៦៩ ដុល្លារ។ |
| ៥.៣ អង្គការមិត្តសំឡាញ់ (MithSamlanh )អនុម័តយល់ព្រមលើប្លង់អាគារនៅក្នុងបរិវេណ ដែលអនុគ្រោះចំពោះការពង្រីកពីមួយឆ្នាំទៅមួយឆ្នាំ។ | - សម្រេចបានប្លង់ពង្រាងនៅត្រីមាសទី៣ នៃឆ្នាំ ២០០៨<br>- សម្រេចចុងក្រោយលើប្លង់ ដោយមានយោបល់ពីប្រភពផ្សេងៗនៅត្រីមាសទី៤ នៃឆ្នាំ២០០៩ | - ពង្រាងប្លង់បានរៀបចំតាំងពី២០០៩។<br>- សម្រេចចុងក្រោយលើប្លង់ ដោយមានយោបល់ពីប្រភពផ្សេងៗបាន សំរេចតាំងពីឆ្នាំ២០០៩។ |
| ៥.៤ អង្គការមិត្តសំឡាញ់ (MithSamlanh )បានកសាងមជ្ឈមណ្ឌលរបស់ខ្លួន។ | - មជ្ឈមណ្ឌលត្រូវបានសាងសង់រួចនៅត្រីមាស ទី៤ នៃឆ្នាំ ២០១១ | - មជ្ឈមណ្ឌលថ្មីមិនទាន់បានចាប់ផ្តើមសាងសង់នៅឡើយ។ |